# មាតិកា


១- រតនត្តយបូជា ........................................ ៤

២- ពុទ្ធរតនប្បណាម ........................................ ៥

៣- ធម្មរតនប្បណាម ........................................ ៩

៤- សង្ឃរតនប្បណាម ........................................ ១៤

៥- យោ កប្បកោដី ........................................ ២០

៦- ធាតុចេតិយនមស្ការគាថា ........................................ ២២

៧- នមស្ការពុទ្ធបាទ ........................................ ២៣

៨- វិធីសមាទានសីល ៥ ........................................ ២៤

៩- វិធីសមាទានសីល ៨ ........................................ ៣០

១០- តេជះខ្ញុំសាង ........................................ ៣៨

១១- បត្តិទានគាថា ........................................ ៣៩

១២- បទសរភញ្ញ ........................................ ៤២

១៣- ធម៌ស្មូត្រលើកទង់ព្រះពុទ្ធសាសនា ........................................ ៤៣

១៤- កំណើតឆព្វណ្ណរង្សី ........................................ ៤៤

១៥- ព្រះពុទ្ធ ២៨ ព្រះអង្គ ........................................ ៤៦

១៦- ឯតទគ្គបាលី-ប្រែ ..........................................៥០

១៧- ធម្មនិយាម ៣០ របស់ព្រះពុទ្ធគ្រប់ព្រះអង្គ ..........៦៣

១៨- រក្សាព្រះត្រៃបិដក ..........................................៦៨

១៩- ខ្ញុំនឹកព្រះណាស់ ..........................................៧០

២០- កណ្តាលទីក្រុងចាស់ ..........................................៧១

២១- កំណាព្យនមស្ការសត្តមហាឋាន ..........................៧២

២២- ឋានត្រៃរតនៈ ..........................................៧៤

២៣- កុសិនារា ..........................................៧៥

២៤- វិសាខបុណ្ណមី ..........................................៧៦

២៥- អដ្ឋមហាឋាន ..........................................៧៧

២៦- បានមកស្រុកព្រះ ..........................................៧៩

២៧- សីលប្រាំ ..........................................៨០

២៨- សុខព្រោះ ..........................................៨២

២៩- ធម៌សូត្រឧទ្ទិសមគ្គផល ..........................................៨៣

៣០- ធម៌សូត្រឧទ្ទិសមគ្គផលម្យ៉ាងទៀត ......................៨៤

៣១- កិច្ចសំខាន់ ៧ ក្នុងព្រះពុទ្ធសាសនា ......................៨៥

៣២- ពុទ្ធកិច្ច ៥ ប្រការដោយសង្ខេប ..........................៨៧
៣៣- ការពិចារណារបស់សុមេធបណ្ឌិត ........................៨៨
៣៤- ពុទ្ធការកធម៌ បារមី ១០......................................៩២
៣៥- សំវេជនីយដ្ឋាន ................................................១០០
៣៦- មង្គល ៣៨ ប្រការ .........................................១០១
៣៧- សេចក្ដីប្រៀបការរលឹកជាតិ របស់បុគ្គល ៦ ពួក ...១០៤
៣៨- មហាបុរិសលក្ខណៈ ៣២ ប្រការ........................១០៥
៣៩- លោកវិទូ ........................................................១១០
៤០- អាយុរបស់ទេវតា ............................................១១៣
៤១- ឧទ្ទិសបុណ្យ ជូនមាតាបិតា ...............................១១៤
៤២- សូមនឹកដល់គុណ ............................................១១៥
៤៣- វិសាខាឧទាន....................................................១១៨

# រតនត្តយបូជា

## *ថ្វាយគ្រឿងសក្ការៈដល់ព្រះរតនត្រ័យ*

**ឥមេហិ ទីបធូបាទិ សក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ អភិបូជយាមិ មាតាបិតាទីនំ គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។**

*ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាម្ចាស់ ដោយគ្រឿង សក្ការៈទាំងឡាយ មាន ទៀន និងធូប ជាដើមនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាផង អស់កាលជាអង្វែងទៅហោង ។*

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ៕**

( សូត្រ ៣ ដង )

វីកិរិយានមស្ការ ថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមាន ដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃ ចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ។

( ក្រាបថ្វាយបង្គំម្តង )

# ពុទ្ធរតនប្បណាម

## ថ្វាយបង្គំព្រះពុទ្ធរតនៈ

**យោ សន្និសិន្នោ វរពោធិមូលេ**

**មារំ សសេនំ មហតឹ វិជេយ្យោ**

**សម្ពោធិមាគច្ឆិ អនន្តញាណោ**

**លោកុត្តមោ តំ បនមាមិ ពុទ្ធំ ៕**

ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់គង់ចម្រើននូវព្រះ-អានាបានស្សតិកម្មដ្ឋាន លើរតនបល្ល័ង្ក ក្រោមម្លប់ពោធិ-

ព្រឹក្សដ៏ប្រសើរ បានផ្ចាញ់នូវមារាធិរាជព្រមទាំងសេនាដ៏ច្រើន ហើយទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ មានប្រាជ្ញារកទីបំផុតគ្មាន ព្រះអង្គប្រសើរជាងសត្វលោក ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធអង្គនោះ ដោយគោរព ។

**យេ ច ពុទ្ធា អតីតា ច យេ ច ពុទ្ធា អនាគតា**

**បច្ចុប្បន្នា ច យេ ពុទ្ធា អហំ វន្ទាមិ សព្វទា ៕**

ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធនិព្វានកន្លងទៅហើយក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលនឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងកាលខាងមុខក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធក្នុងកទ្ទកប្បនេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ គ្រប់កាលទាំងពួង ។ ( ក្រាបថ្វាយបង្គំម្តង )

**ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណ~សម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថាទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។**

**ឥតិបិ សោ ភគវា អរហំ** *ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា* ***អរហំ*** *ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវ ពោល គឺកិលេស ព្រមទាំងវាសនា គឺកាយបយោគ និង វចីបយោគ* **សម្មាសម្ពុទ្ធោ** *ទ្រង់ព្រះនាមថា* ***សម្មាសម្ពុទ្ធោ*** *ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃ ចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ* **វិជ្ជាចរណសម្បន្នោ** *ទ្រង់ព្រះនាមថា* ***វិជ្ជាចរណសម្បន្នោ*** *ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា ៣ និងវិជ្ជា ៨ និងចរណៈ ១៥* **សុគតោ** *ទ្រង់ព្រះនាមថា* ***សុគតោ*** *ព្រោះព្រះអង្គមាន ដំណើរល្អ យាងទៅកាន់សុន្ទរស្ថាន គឺអមតមហានិព្វាន* **លោកវិទូ** *ទ្រង់ព្រះនាមថា* ***លោកវិទូ*** *ព្រោះព្រះអង្គទ្រង់ ជ្រាបច្បាស់នូវត្រៃលោក* **អនុត្តរោ** *ទ្រង់ព្រះនាមថា* ***អនុត្តរោ***

ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន **បុរិសទម្មសារថិ** ទ្រង់ព្រះនាមថា ***បុរិសទម្មសារថិ*** ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរសដែល មានឧបនិស្ស័យគួរនឹងទូន្មានបាន **សត្ថាទេវមនុស្សានំ** ទ្រង់ព្រះនាមថា ***សត្ថាទេវមនុស្សានំ*** ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតា និងមនុស្សទាំងឡាយ **ពុទ្ធោ** ទ្រង់ព្រះនាមថា ***ពុទ្ធោ*** ព្រោះព្រះអង្គទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច ហើយញ៉ាំងអ្នកដទៃឲ្យត្រាស់ដឹងផង **ភគវា** ទ្រង់ព្រះនាមថា ***ភគវា*** ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភព ខ្ជាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។

( ក្រាបថ្វាយបង្គំមួង )

**នត្ថិ មេ សរណំ អញ្ញំ**

**ពុទ្ធោ មេ សរណំ វរំ**

**ឯតេន សច្ចវជ្ជេន**

**ហោតុ មេ ជយមង្គលំ ។**

**នត្ថិ មេ សរណំ អញ្ញំ** *វត្ថុដទៃជាទីពឹង ទីរឭក នៃខ្ញុំព្រះករុណាមិនមានឡើយ* **ពុទ្ធោ មេ សរណំ វរំ** *មានតែព្រះពុទ្ធជាម្ចាស់ ជាទីពឹង ទីរឭក ដ៏ប្រសើររបស់ខ្ញុំព្រះ-ករុណា* **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** *សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។*

*( ក្រាបថ្វាយបង្គំម្តង )*

**ឧត្តមង្គេន វន្ទេហំ**

**បាទបំសុំ វរុត្តមំ**

**ពុទ្ធេ យោ ខលិតោ ទោសោ**

**ពុទ្ធោ ខមតុ តំ មមំ ។**

**ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ** *ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវល្អងធូលីព្រះបាទ នៃព្រះសម្មាសម្ពុទ្ធ ដ៏ប្រសើរខ្ពង់ខ្ពស់ ដោយអវយវៈដ៏ឧត្តម គឺត្បូង* **ពុទ្ធេ យោ ខលិតោ ទោសោ** *ទោសឯណា ដែលខ្ញុំព្រះករុណា ធ្វើឲ្យ*

*ភ្ញាំងភ្ញាត់ហើយក្នុងព្រះពុទ្ធជាម្ចាស់* **ពុទ្ធោ ខមតុ តំ មមំ**
*សូមព្រះពុទ្ធជាម្ចាស់ អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។*

*( ក្រាបថ្វាយបង្គំម្តង )*

# ធម្មរតនប្បណាម

## *ថ្វាយបង្គំព្រះធម្មរតនៈ*

**អដ្ឋង្គិការិយបថោ ជនានំ**

**មោក្ខប្បវេសាយ ឧជូ ច មគ្គោ**

**ធម្មោ អយំ សន្តិករោ បណីតោ**

**និយ្យានិកោ តំ បនមាមិ ធម្មំ ។**

*ព្រះសទ្ធម្មឯណា ជាធម៌ប្រកបដោយអង្គ ៨ ប្រការ ជាគន្លងដំណើរនៃព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់ក្នុងកិរិយា ញ៉ាំងជនដែលប្រាថ្នានូវព្រះនិព្វាន ឲ្យចូលទៅកាន់ព្រះនិព្វានបាន ព្រះធម៌នេះ ជាធម៌ធ្វើឲ្យត្រជាក់ រំងាប់បង់នូវភ្លើងទុក្ខ ភ្លើងកិលេស ជាធម៌ដ៏ឧត្តម ជាគុណញ៉ាំងសត្វ*

ឲ្យចេញចាកសង្សារទុក្ខ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសទ្ធម្មនោះ ដោយគោរព ។

( ក្រាបថ្វាយបង្គំម្តង )

**យេ ច ធម្មា អតីតា ច យេ ច ធម្មា អនាគតា**
**បច្ចុប្បន្នា ច យេ ធម្មា អហំ វន្ទាមិ សព្វទា ។**

ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ដែលនិព្វានកន្លងទៅហើយក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ នឹងមានមកក្នុងកាលខាងមុខក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុកក្នុងកាលសព្វថ្ងៃនេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធម៌ទាំងឡាយនោះ គ្រប់កាលទាំងពួង ។

( ក្រាបថ្វាយបង្គំម្តង )

**ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ**
**ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។**

**ស្វាក្ខាតោ ភគវតា ធម្មោ** ព្រះបរិយត្តិធម៌ គឺព្រះ-ត្រៃបិដក ជាធម៌គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្ដែងហើយដោយល្អ ( **ធម្មោ** ព្រះនព្វលោកុត្តរធម៌ មាន ៩ ប្រការ គឺមគ្គ ៤ ផល ៤ និព្វាន ១ ) **សន្ទិដ្ឋិកោ** ជាធម៌គឺព្រះអរិយបុគ្គលទាំងពួង ដឹងពិត ឃើញពិត ដោយបច្ច-វេក្ខណញ្ញាណ គឺថា នឹងបានដឹងដោយស្ដាប់ ដោយជឿបុគ្គលដទៃនោះ ៗ ក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង **អកាលិកោ** ជាធម៌ឲ្យនូវផលមិនរង់ចាំកាល គឺថា កាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផលក៏កើតក្នុងលំដាប់គ្នា មិនបានឃើតយូរឡើយ **ឯហិបស្សិកោ** ជាធម៌គួរដល់ឯហិបស្សវិធី គឺថា បើព្រះអរិយបុគ្គល ដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃ ឲ្យចូលមកមើលបាន **ឱបនយិកោ** ជាធម៌ គឺព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួន ដោយអំណាចនៃភាវនា **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ជាធម៌ គឺអ្នកប្រាជ្ញទាំងឡាយ មាន

ឧត្ដុងជិតញ្ញាបុគ្គលជាដើម គប្បីដឹង គប្បីឃើញច្បាស់ ក្នុងចិត្តនៃខ្លួន ។

( ក្រាបថ្វាយបង្គំម្ដង )

**នត្ថិ មេ សរណំ អញ្ញំ**

**ធម្មោ មេ សរណំ វរំ**

**ឯតេន សច្ចវជ្ជេន**

**ហោតុ មេ ជយមង្គលំ ។**

**នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹង ទីរឭក នៃខ្ញុំព្រះករុណា មិនមានឡើយ **ធម្មោ មេ សរណំ វរំ** មានតែព្រះធម៌ជាម្ចាស់ ជាទីពឹង ទីរឭក ដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្ដីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

( ក្រាបថ្វាយបង្គំម្ដង )

**ឧត្តមង្គេន វន្ទេហំ**

**ធម្មញ្ច ទុវិធំ វរំ**

**ធម្មេ យោ ខលិតោ ទោសោ**

**ធម្មោ ខមតុ តំ មមំ ។**

**ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ** *ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះធម៌ដ៏ប្រសើរ មាន ២ ប្រការ គឺព្រះ-បរិយត្តិធម៌ និងព្រះនព្វលោកុត្តរធម៌ ដោយអវយវៈដ៏ឧត្តម គឺត្បូង* **ធម្មេ យោ ខលិតោ ទោសោ** *ទោសឯណា ដែលខ្ញុំព្រះករុណា ធ្វើឲ្យភ្លាំងភ្លាត់ហើយក្នុងព្រះធម៌ជាម្ចាស់* **ធម្មោ ខមតុ តំ មមំ** *សូមព្រះធម៌ជាម្ចាស់ អត់នូវទោស នោះដល់ខ្ញុំព្រះករុណា ។* *( ក្រាបថ្វាយបង្គំម្តង )*

**៣៣៤- ឆេវឆាវ...រម្ងាប់ដោយពិចារណា**

**វៀចវេរមុសា...រម្ងាប់ដោយចិត្តស្មោះ**

**គំនុំគុំគួន ...រម្ងាប់ដោយអនុគ្រោះ**

**ទោសកំហុស ...រម្ងាប់ដោយស្មារតី ។**

# សង្ឃរតនប្បណាម

## ថ្វាយបង្គំព្រះសង្ឃរតនៈ

**សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ**

**សន្តិន្ទ្រិយោ សព្វមលប្បហីនោ**

**គុណេហិ នេកេហិ សមិទ្ធិបត្តោ**

**អនាសវោ តំ បនមាមិ សង្ឃំ ។**

*ព្រះអរិយសង្ឃឯណា ដ៏បរិសុទ្ធវិសេស ជាទក្ខិណេយ្យ បុគ្គលដ៏ប្រសើរ មានឥន្ទ្រិយរំងាប់ហើយ មានមន្ទិល គឺរាគាទិក្កិលេសទាំងពួង បន្សាត់បង់ហើយ ជាព្រះសង្ឃដល់ហើយ នូវកិរិយាសម្រេចដោយគុណទាំងឡាយដ៏ច្រើន ជាព្រះសង្ឃមានអាសវធម៌មិនមាន គឺថា ជាព្រះខីណាស្រព ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះអរិយសង្ឃនោះ ដោយគោរព ។*

*( ក្រាបថ្វាយបង្គំម្តង )*

**យេ ច សង្ឃា អតីតា ច យេ ច សង្ឃា អនាគតា**

**បច្ចុប្បន្នា ច យេ សង្ឃា អហំ វន្ទាមិ សព្វទា ។**

*ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គ និងផល កន្លងទៅហើយក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃនឹងបានសម្រេចមគ្គ និងផល ក្នុងកាលខាងមុខក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គ និងផល ក្នុងកាលជាបច្ចុប្បន្ននេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវ ព្រះសង្ឃទាំងឡាយនោះ គ្រប់កាលទាំងពួង ។*

*( ក្រាបថ្វាយបង្គំម្តង )*

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ញាយបដិបន្នោ ភគវតោ សាវក~សង្ឃោ សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ**

**សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។**

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌ **ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមប្បដិបទា **ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាស្ថានក្សេមផុតចាកទុក្ខទាំងពួង **សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា **យទិទំ ចត្តារិ បុរិសយុគានិ** ព្រះសង្ឃឯណាបើរាប់ជាគូនៃបុរសទាំងឡាយមាន ៤ គូ គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ

និងសោតាបត្តិផល ជាគូ ១ សកទាគាមិមគ្គ និងសកទា-គាមិផល ជាគូ ១ អនាគាមិមគ្គ និងអនាគាមិផល ជាគូ ១ អរហត្តមគ្គ និងអរហត្តផល ជាគូ ១ **អដ្ឋបុរិសបុគ្គលា** បើរាប់រៀងជាបុរសបុគ្គល មាន ៨ គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ ១ សោតាបត្តិផល ១ សកទា-គាមិមគ្គ ១ សកទាគាមិផល ១ អនាគាមិមគ្គ ១ អនាគា-មិផល ១ អរហត្តមគ្គ ១ អរហត្តផល ១ **ឯស ភគវតោ សាវកសង្ឃោ** ព្រះសង្ឃទាំងនោះ ជាសង្ឃសាវកនៃព្រះដ៏-មានព្រះភាគ **អាហុនេយ្យោ** លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយ បង្អោនចូលមកបូជា **បាហុនេយ្យោ** លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់តែងដើម្បីញាតិ និងមិត្ត ដែលមកអំពីទិសផ្សេង ៗ ហើយបង្អោនចូលមកបូជា **ទក្ខិណេយ្យោ** លោកគួរទទួលនូវទាន ដែលបុគ្គលជឿនូវកម្ម និងផលនៃកម្ម ហើយបូជា **អញ្ជលិករណីយោ** លោកគួរ

*ទទួលដល់អញ្ជលីកម្ម ដែលសត្វលោកគប្បីធ្វើ* **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** *លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោករកខេត្តដទៃ ក្រៃលែងជាងគ្មាន ។*

**នត្ថិ មេ សរណំ អញ្ញំ**

**សង្ឃោ មេ សរណំ វរំ**

**ឯតេន សច្ចវជ្ជេន**

**ហោតុ មេ ជយមង្គលំ ។**

**នត្ថិ មេ សរណំ អញ្ញំ** *វត្ថុដទៃជាទីពឹង ទីរឭកនៃខ្ញុំព្រះករុណា មិនមានឡើយ* **សង្ឃោ មេ សរណំ វរំ** *មានតែព្រះសង្ឃជាម្ចាស់ជាទីពឹង ទីរឭកដ៏ប្រសើរ របស់ខ្ញុំព្រះ-ករុណា* **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** *សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។*

**ឧត្តមង្គេន វន្ទេហំ**

**សង្ឃញ្ច ទុវិធោត្តមំ**

**សង្ឃេ យោ ខលិតោ ទោសោ**

**សង្ឃោ ខមតុ តំ មមំ ។**

**ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ** *ខ្ញុំព្រះ-ករុណា សូមថ្វាយបង្គំនូវព្រះសង្ឃដ៏ប្រសើរ មាន ២ ប្រការ គឺសម្មតិសង្ឃ និងអរិយសង្ឃ ដោយអវយវៈដ៏ឧត្តម គឺត្បូង* **សង្ឃេ យោ ខលិតោ ទោសោ** *ទោសឯណា ដែលខ្ញុំព្រះករុណា ធ្វើឲ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះសង្ឃជាម្ចាស់* **សង្ឃោ ខមតុ តំ មមំ** *សូមព្រះសង្ឃជាម្ចាស់អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។*

*( ក្រាបថ្វាយបង្គំម្តង )*

**ចប់ត្រៃបណាមពិស្តារ**

# យោកប្បកោដីហិបិ

**យោ កប្បកោដីហិបិ អប្បមេយ្យំ**

**កាលំ ករោន្តោ អតិទុក្ករានិ**

**ខេទំ គតោ លោកហិតាយ នាថោ**

**នមោ មហាការុណិកស្ស តស្ស ។**

*ព្រះពុទ្ធជាទីពឹង ជាពំនឹងសព្វសត្តា ព្រះអង្គកាលប្រាថ្នា ធ្វើកសាងអស់កាលយូរ រាប់ដោយកោដិកប្បា ច្រើនគណនាហួសគិតគូ បានត្រាស់ជាសព្វញ្ញូ ត្រាស់ជាគ្រូលើភពឋាន ធ្វើកម្មជាកម្រ សត្តនិករត្រាប់ពុំបាន តោកយ៉ាកលំបាកប្រាណ ព្រោះប្រយោជន៍ដល់សព្វសត្វ ខ្ញុំសូមឱនសិរសា ចិត្តប្រាថ្នាបង្គំថ្វាត់ ព្រះពុទ្ធករុណាសត្វ នោះជាទីពឹងសព្វកាល ។*

**អសម្ពុធំ ពុទ្ធនិសេវិតំ យំ**

**ភវាភវំ គច្ឆតិ ជីវលោកោ**

**នមោ អវិជ្ជាទិកិលេសជាលំ**

**វិទ្ធំសិនោ ធម្មវរស្ស តស្ស ។**

*សត្វតែងកើតស្លាប់បង់ ព្រោះចំណងកម្មជាគោល ឲ្យវិលវល់អន្ទោល ក្នុងកពតូចនិងកពធំ ហេតុតែមិនដឹងធម៌ ជាម្ចាស់ល្អស្អាតសុខុម គឺព្រះពុទ្ធសេពសម ចិត្តខ្ញុំសូម-នមស្ការ នូវធម៌ប្រពៃពិត វិសេសសុទ្ធនោះឯងណា កាត់-បង់នូវអវិជ្ជា គឺបណ្ដាញកិលេសហើយ ។*

**គុណេហិ យោ សីលសមាធិបញ្ញា-**

**វិមុត្តិញ្ញាណប្បភូតីហិ យុត្តោ**

**ខេត្តញ្ញនានំ កុសលត្ថិកានំ**

**តមរិយសង្ឃំ សិរសា នមាមិ ។**

*ព្រះសង្ឃអង្គសាវក មានសំវរៈសទ្ធាទ្រទ្រង់ កបដោយ-គុណសីលត្រង់ និងសមាធិបញ្ញា និងវិមុត្តិញាណ កិលេសគ្មានក្នុងអាត្មា ជាបុញ្ញក្ខេត្តា ជនត្រូវការជាកុសល*

*ខ្ញុំសូមឱនសិរសី ដល់ព្រះអរិយបុគ្គល ជាបុត្រព្រះទសពល ជាមង្គលដល់សព្វសត្វ ។*

**ឥច្ចេវមច្ចន្ត នមស្សនេយ្យំ**

**នមស្សមានោ រតនត្តយំ យំ**

**បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ**

**តស្សានុភាវេន ហតន្តរាយោ ។**

*ខ្ញុំសូមនមស្ការ លើកហត្ថាឱនសិរសី បង្គំគុណទាំងបីខ្ពស់លើសលប់ត្រៃលោកា សូមបុណ្យកងកុសល ឲ្យបានដល់យើងខ្ញុំណា ពេញពោរស្មើធារា ដូចជលសាធំទូលាយ សូមឲ្យកម្ចាត់បង់ អពមង្គលទាំងឡាយ ឲ្យចៀសចេញចាកឆ្ងាយ ក្តីអន្តរាយកុំបីមាន ដោយកម្លាំងអានុភាព បុញ្ញលាភជាប្រធាន កងបុញ្ញរាសីមាន សូមបានក្សាន្តកុំមានមោះ ដោយគុណនមស្ការ ត្រៃរតនាប្រសើរខ្ពស់ សូមអានិសង្សនោះ ដាក់ដល់ឋាននិព្វានហោង ។*

# ធាតុចេតិយនមស្ការគាថា

**វន្ទាមិ ចេតិយំ សព្វំ**

**សព្វដ្ឋានេសុ បតិដ្ឋិតំ**

**សារីរិកធាតុ មហាពោធឹ**

**ពុទ្ធរូបំ សកលំ សទា ។**

ខ្ញុំសូមថ្វាយបង្គំ ចំពោះព្រះបរមចេតិយ ព្រមទាំងព្រះសារី រិកធាតុនៃព្រះពុទ្ធ និងមហាពោធិព្រឹក្ស ដែលគួរនឹកដោយលំអុត លំឱនចិត្តបរិសុទ្ធ លើកកំបង់អញ្ជលី និងព្រះពុទ្ធរូប តំណាងអង្គព្រះមុនី ដែលឋិតនៅគ្រប់ទីឋាននានានោះទាំងអស់ ដោយតេជះនៃគុណ ព្រះមានបុណ្យប្រសើរខ្ពស់ ដែលតែងតែរំលស់ រំដោះទុក្ខភ័យអន្តរាយ សូមឲ្យខ្ញុំបានសុខ ឃ្លាតចាកទុក្ខផងទាំងឡាយ សត្រូវទោះជិតឆ្ងាយ សូមឲ្យក្លាយមកជាមិត្ត សូមទាន់ព្រះអរិយ យមេត្រេយ្យថ្ងៃវិសិដ្ឋ សូមបានឃើញធម៌ពិត សមដូចចិត្តប្រាថ្នាហោង ។

# នមស្ការពុទ្ធបាទ

**វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ**

**តិលោកកេតុំ តិភវេកនាថំ**

**យោ លោកសេដ្ឋោ សកលំ កិលេសំ**

**ឆេត្វាន ពោធេសិ ជនំ អនន្តំ ។**

ព្រះសម្មាសម្ពុទ្ធឯណា ព្រះអង្គប្រសើរក្នុងលោក ទ្រង់កាត់បង់នូវកិលេស ទាំងអស់បានហើយ ញុំាំងជនជាអនន្ត ឲ្យត្រាស់ដឹងហើយ ខ្ញុំសូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធនោះ ព្រះអង្គឆ្លងផុត អំពីប្រាំងនៃភពហើយ ព្រះអង្គជាទង់ជ័យ នៃត្រៃលោក មានតែព្រះអង្គមួយ ជាទីពឹងនៃ សព្វសត្វក្នុងត្រៃភព ។

**យំ នម្មទាយ នទិយា បុលិនេ ច តីរេ**

**យំ សច្ចពន្ធគិរិកេ សុមនា ច លគ្គេ**

**យំ តត្ថ យោនកបុរេ មុនិនោ ច បាទំ**

**តំ បាទលញ្ឆនមហំ សិរសា នមាមិ ។**

ស្នាមព្រះបាទ ឯណា ( ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក ) លើផ្នូរខ្សាច់ ទៀបឆ្នេរនៃស្ទឹងឈ្មោះនម្មទា ស្នាមព្រះបាទឯណា ( ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក ) លើភ្នំសច្ចពន្ធ និងលើភ្នំសុមនកូដ ស្នាមព្រះបាទឯណា ( ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក ) ក្នុងយោនកបុរី ខ្ញុំសូមក្រាបថ្វាយបង្គំដោយត្បូង ចំពោះទៅព្រះបាទ និងស្នាមព្រះបាទទាំងនោះ នៃព្រះសក្យមុនី ។

**សុវណ្ណមាលិកេ សុវណ្ណបព្វតេ សុមនកូដេ យោនក~បុរេ នម្មទាយ នទិយា បញ្ចបាទវរំ ឋានំ អហំ វន្ទាមិ ទូរតោ ។**

ខ្ញុំសូមនមស្ការអំពីចម្ងាយ នូវស្ថានដែលមាន ព្រះ-បាទដ៏ប្រសើរ ៥ កន្លែង គឺស្ថានលើភ្នំសុវណ្ណមាលិក ១ លើភ្នំសុវណ្ណបព៌ត ១ លើភ្នំសុមនកូដ ១ ក្នុងយោនកបុរី ១ ក្បែរស្ទឹងនម្មទា ១ ។

# វិធីសមាទានសីល ៥ ( និច្ចសីល )

**ឱកាស អហំ / មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចសីលានិ យាចាមិ / យាចាម ។**

**ទុតិយម្បិ អហំ / មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចសីលានិ យាចាមិ / យាចាម ។**

**តតិយម្បិ អហំ / មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចសីលានិ យាចាមិ / យាចាម ។**

*សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ សូមសមាទាននូវសីលទាំងឡាយ ៥ មួយអន្លើ ដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា ។ បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តា ឲ្យនូវសីលដល់ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ ដោយសេចក្តី*

អនុគ្រោះ ។ បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ សូមសមាទាននូវសីលទាំងឡាយ ៥ មួយអន្លើ ដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា ។ បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាឲ្យនូវសីលដល់ខ្ញុំព្រះករុណា / ខ្ញុំព្រះ-ករុណាទាំងឡាយ ដោយសេចក្តីអនុគ្រោះ ជាគម្រប់ ២ ដងផង ។ បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ សូមសមាទាននូវសីលទាំងឡាយ ៥ មួយអន្លើ ដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា ។ បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះ-ករុណា មេត្តាឲ្យនូវសីលដល់ខ្ញុំព្រះករុណា / ខ្ញុំ ព្រះករុណាទាំងឡាយ ដោយសេចក្តីអនុគ្រោះ ជាគម្រប់ ៣ ដងផង ។

# លោកអ្នកឲ្យសីលសូត្រ

## (អ្នកសុំសីល ត្រូវសូត្រតាមលោក )

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ៕**

**( សូត្រ ៣ ដង )**

វីកិរិយានមស្ការ ថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ។

**ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹង ទីរឭក ។

**ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹង ទីរឭក ។

**សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹង ទីរឭក ។

**ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹង ទីរឮក ជាគម្រប់ ២ ដងផង ។

**ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹង ទីរឮក ជាគំរប់ ២ ដងផង ។

**ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីពឹង ទីរឮក ជាគម្រប់ ២ ដងផង ។

**តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹង ទីរឮក ជាគម្រប់ ៣ ដងផង ។

**តតិយម្បិ ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីពឹង ទីរឮក ជាគម្រប់ ៣ ដងផង ។

**តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីពឹង ទីរឮក ជាគម្រប់ ៣ ដងផង ។

<u>ហើយលោកសូត្រថា</u> **តិសរណគ្គហណំ បរិបុណ្ណំ** កិរិយាកាន់នូវព្រះត្រៃសរណគមន៍ បរិបូណ៌តែប៉ុណ្ណេះ ។

អ្នកសូមសីលថា អាម ភន្តេ ករុណា លោកម្ចាស់ ។

បន្ទាប់មក លោកឲ្យសីល ៥ ថាដូច្នេះ

**បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

**អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុ ដែលគេមិនបានឲ្យដោយកាយ ឬដោយវាចា ។

**កាមេសុមិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

**មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

**សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ** *ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ។*

*<u>ហើយលោកសូត្រថា</u>* **ឥមានិ បញ្ច សិក្ខាបទានិ សាធុកំ កត្វា អប្បមាទេន និច្ចកាលំ សម្មារក្ខិតព្វំ ។** *អ្នក ! អ្នកទាំងឡាយ គប្បីធ្វើនូវសិក្ខាបទទាំងឡាយ ៥ នេះ ឲ្យប្រពៃ ត្រូវរក្សាឲ្យល្អអស់កាលជានិច្ច ដោយសេចក្ដីមិនប្រមាទ គឺជាកុំធ្វេសប្រហែសឡើយ ។*

# វិធីសមាទានសីល ៨ (ឧបោសថសីល)

ឧកាស អហំ / មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋ សីលានិ / អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាមិ / យាចាម ។ ទុតិយម្បិ អហំ / មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋ សីលានិ / អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាមិ / យាចាម ។ តតិយម្បិ អហំ / មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋ សីលានិ / អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាមិ / យាចាម ។

*សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ សូមនូវឧបោសថសីល ប្រកបដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍*

ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា ។ បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្ដីអនុគ្រោះឲ្យនូវសីលដល់ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ ។ បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ សូមសមាទាននូវឧបោសថសីល ប្រកបដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា ជាគម្រប់ ២ ដងផង ។ បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្ដីអនុគ្រោះឲ្យនូវសីល ដល់ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ ។ បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ សូមសមាទាននូវឧបោសថសីល ប្រកបដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា ជាគម្រប់ ៣ ដងផង ។ បពិត្រព្រះករុណាដ៏ចម្រើន

*សូមព្រះករុណា មេត្តាធ្វើនូវ សេចក្ដីអនុគ្រោះឲ្យនូវសីល ដល់ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ ។*

*លោកអ្នកឲ្យសីលសូត្រ*

*( អ្នកសុំសីល ត្រូវសូត្រតាមលោក )*

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។**

**( សូត្រ ៣ ដង )**

*រីកិរិយានមស្ការ ថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមាន ដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃ ចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ។*

**ពុទ្ធំ សរណំ គច្ឆាមិ** *ខ្ញុំព្រះករុណា សូមដល់នូវ ព្រះពុទ្ធជាទីពឹង ទីរឭក ។*

**ធម្មំ សរណំ គច្ឆាមិ** *ខ្ញុំព្រះករុណា សូមដល់នូវ ព្រះធម៌ជាទីពឹង ទីរឭក ។*

**សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹង ទីរឭក ។

**ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹង ទីរឭក ជាគម្រប់ ២ ដងផង ។

**ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹង ទីរឭក ជាគម្រប់ ២ ដងផង ។

**ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីពឹង ទីរឭក ជាគម្រប់ ២ ដងផង ។

**តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹង ទីរឭក ជាគម្រប់ ៣ ដងផង ។

**តតិយម្បិ ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីពឹង ទីរឭក ជាគម្រប់ ៣ ដងផង ។

**តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីពឹង ទីរឭក គម្រប់ ៣ ដងផង ។

ហើយលោកសូត្រថា **តិសរណគ្គហណំ បរិបុណ្ណំ** កិរិយាកាន់នូវព្រះត្រៃសរណគមន៍ បរិបូណ៌តែប៉ុណ្ណេះ ។

អ្នកសូមសីលថា **អាម ភន្តេ ករុណា** លោកម្ចាស់ ។

បន្ទាប់មក លោកឲ្យសីល ៨ ថាដូច្នេះ

**បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

**អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុ ដែលគេមិនបានឲ្យដោយកាយ ឬដោយវាចា ។

**អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តនូវធម៌មិនប្រសើរ គឺសេពមេថុនធម្ម ។

**មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

**សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមា~ទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ។

**វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាបរិភោគនូវភោជនាហារ ក្នុងកាលខុស ។

**នច្ចគីតវាទិតវិសូកទស្សនមាលាគន្ធ វិលេបនធារណ~មណ្ឌន វិភូសនដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយារាំ និងច្រៀង និងប្រគំ និងមើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌ និងកិរិយាទ្រទ្រង់ និង

ប្រដាប់តាក់តែង ស្អិតស្អាងរាងកាយ ដោយផ្កាកម្រង និងគ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ ។

**ឧច្ចាសយន មហាសយនា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកទីសេនាសនៈ ដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ ។

<u>បន្ទាប់ពីសមាទានសីល ៨ រួចហើយ អ្នកសូមសីល ត្រូវសូត្រ កំណត់ឧបោសថ ជាដូច្នេះ</u>

**ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សម្មទេវ អភិរក្ខិតុំ សមាទិយាមិ ៗ** ខ្ញុំព្រះករុណា សូមសមាទាននូវឧបោសថសីល ដ៏ប្រកប ដោយអង្គ ៨ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ បញ្ញត្តទុកហើយនេះ ដើម្បីនឹងរក្សាឲ្យបរិបូណ៌ប្រពៃ អស់កាលកំណត់ថ្ងៃនេះ និងយប់នេះ សូមកុសល ចូរជាឧបនិស្ស័យ ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ក្នុងអនាគតទៅឯខាងមុខហោង ។

<u>ហើយលោកសូត្រថា</u> **ឥមានិ អដ្ឋ សិក្ខាបទានិ ឧបោសថ សីលវសេន ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សាធុកំ កត្វា អប្បមាទេន សម្មារក្ខិតព្វំ ។** *អ្នកទាំងឡាយ គប្បីធ្វើនូវសិក្ខាបទទាំងឡាយ ៨ នេះ ឲ្យប្រពៃ ត្រូវរក្សាឲ្យល្អ ដោយអំណាចនៃឧបោសថ អស់កាលកំណត់ត្រឹម ១ ថ្ងៃ ១ យប់នេះ ដោយសេចក្ដីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។*

<u>រូបអ្នកសូមសីលសូត្រថា</u> **អាម ភន្តេ** *ករុណាលោកម្ចាស់ ។*

<u>លោកសូត្របន្តទៀតថា</u> **សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ។** *សត្វទាំងឡាយ ទៅកាន់បានសុគតិបាន ក៏ព្រោះសីល សត្វទាំងឡាយ បានបរិបូណ៌ដោយភោគ ក៏ព្រោះសីល សត្វទាំងឡាយ បានទៅកាន់ទីរំលត់*

ទុក្ខ គឺព្រះនិព្វាន ក៏ព្រោះសីល ព្រោះហេតុនេះ បុគ្គលជាសប្បុរស គប្បីជម្រះនូវសីល ឲ្យបរិសុទ្ធ កុំបីសៅហ្មង ។

**<u>អ្នកសូមសីលពោលថា</u>** **សាធុ** ប្រពៃហើយ ។

# គេជះខ្ញុំសាង

គេជះខ្ញុំសាង សំអិតសំអាង ឱនកាយវាចា សូម-សុខសោភា រួចពីទុក្ខា ឆ្លងដល់ត្រើយមហា ពោលគឺនិព្វាន ។ គ្រប់ជាន់គ្រប់ជាតិ កុំឲ្យខ្ញុំឃ្លាត ពីសីលនិងទាន គំនិតខ្ញុំកើត កំណើតខ្ញុំមាន មគ្គផលជាស្ពាន ដល់ស្ថានថ្ងៃថ្លា ។ ខ្ញុំជូនមគ្គផល ចំពោះទៅដល់ មាតាបិតា គុណគ្រូឧបជ្ឈា-យាចារ្យ គុណញាតិកា ក្នុងសង្សារវដ្ដ ។ ជីដូនជីតា រស់នៅក្តីណា លោកម្ចាស់ចែកស្ថាន សូមជូនមគ្គផល កុសលច្រើនក្តាន សូមសុខក្សេមក្សាន្ត ដល់ស្ថានផុតទុក្ខ ។ ខ្ញុំសូមសច្ចា កើតជាតិណាៗ សូមឲ្យខ្ញុំសុខ សូមមានបញ្ញា ភ្លឺថ្លាមោះមុត រួចផុតពីទុក្ខ ដល់និព្វានហោង ។

# បត្តិទានគាថា

យំ កិញ្ចិ កុសលកម្មំ    កត្តព្វំ កិរិយំ មម
កាយេន វាចា មនសា    តិទសេ សុគតំ កតំ
យេ សត្តា សញ្ញិនោ អត្ថិ    យេ ច សត្តា អសញ្ញិនោ
កតំ បុញ្ញផលំ មយ្ហំ    សព្វេ ភាគី ភវន្តុ តេ
យេ តំ កតំ សុវិទិតំ    ទិន្នំ បុញ្ញផលំ មយា
យេ ច តត្ថ ន ជានន្តិ    ទេវា គន្ត្វា និវេទយុំ
សព្វេ លោកម្ហិ យេ    សត្តា ជីវន្តាហារហេតុកា
មនុញ្ញំ ភោជនំ សព្វេ    លភន្តុ មម ចេតសាតិ ។

**យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម** *អំពើជាកុសលឯណាមួយ ដែលខ្ញុំគប្បីធ្វើ* **កាយេន វាចា មនសា** *ដោយទ្វារទាំង ៣ គឺកាយ វាចា ចិត្ត* **តិទសេ សុគតំ កតំ** *អំពើជាកុសលទាំងអស់នោះ ដែលខ្ញុំបានធ្វើហើយ ជាកុសល អាចនឹងនាំឲ្យទៅកើតក្នុងឋានត្រៃត្រឹង្ស*

ស្ងួតបាន **យេ សត្តា សញ្ញិនោ អត្ថិ** សត្វទាំងឡាយ ឯណា គឺមនុស្ស ឬទេវតា ឬព្រហ្ម ដែលជាសត្វមាន សញ្ញាក្តី **យេ ច សត្តា អសញ្ញិនោ** សត្វទាំងឡាយ ជាអសញ្ញីសត្វ គឺសត្វដែលឥតសញ្ញាក្តី **កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ** សត្វទាំងឡាយ ទាំងអស់ នោះ ចូរឲ្យបាននូវចំណែកផលនៃបុណ្យហើយ ចូរសោយ ផលនៃបុណ្យ ដែលខ្ញុំបានធ្វើហើយ បានឧទ្ទិសផ្សាយឲ្យ ទៅនេះចុះ **យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា** បុណ្យដែលខ្ញុំបានធ្វើហើយនោះ បើសត្វទាំងឡាយឯណា បានដឹងច្បាស់ហើយ សត្វទាំងឡាយនោះ ចូរឲ្យបាន សោយនូវផលនៃបុណ្យ ដែលខ្ញុំបានឧទ្ទិសឲ្យទៅនោះចុះ **យេ ច តត្ថ ន ជានន្តិ**ម្យ៉ាងទៀត បណ្តាអស់សត្វទាំង នោះ បើសត្វទាំងឡាយឯណា មិនបានដឹងនូវបុណ្យ ដែលខ្ញុំបានធ្វើហើយនោះ **ទេវា គន្ត្វា និវេទយុំ** សូម ទេវតាទាំងឡាយ អញ្ជើញទៅឲ្យដំណឹងដល់សត្វទាំងឡាយ

នោះ ឲ្យបានដឹងផងថា ជនឯណោះ គេបានធ្វើបុណ្យហើយ គេឧទ្ទិសផ្សាយផលបុណ្យនោះ មកដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរអនុមោទនាត្រេកអរនឹងបុណ្យគេនោះចុះ **សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា** សត្វទាំងឡាយឯណា ក្នុងលោកទាំងអស់ ដែលអាស្រ័យនូវអាហារហើយរស់នៅ **មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសាតិ** សត្វទាំងឡាយ ទាំងអស់នោះ ចូរឲ្យបាននូវភោជនជាទីគាប់ចិត្ត ដែលសម្រេចដោយបុញ្ញឫទ្ធិតាមចិត្ត ដែលខ្ញុំឧទ្ទិសផ្សាយទៅឲ្យនេះចុះ ។

**ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា សោកប្បត្តោ ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ ។**

សត្វទាំងឡាយទាំងពួង ដែលដល់ហើយនូវសេចក្តីទុក្ខ សូមឲ្យជាសត្វបាត់សេចក្តីទុក្ខទៅ ដែលដល់ហើយនូវភ័យ សូមឲ្យជាសត្វបាត់ភ័យទៅ ដែលដល់ហើយនូវសេចក្តីសោក សូមឲ្យជាសត្វបាត់សេចក្តីសោកទៅហោង ។

# បទសភព្វ

សូមថ្វាយបង្គំ-ព្រះសម្ពុទ្ធ ប្រសើរបំផុត-ក្នុងលោកា
ជាគ្រូនៃមនុស្ស-និងទេវតា ទ្រង់ត្រាស់ទេសនា-ប្រដៅសត្វ
ចង្អុលឱ្យដើរ-ផ្លូវកណ្ដាល មាគ៌ាត្រកាល-អាចកម្ចាត់
ទុក្ខភ័យចង្រៃ-ឱ្យខ្លាយបាត់ អាចកាត់សង្សា-រៈទុក្ខបាន ។

សាសនាព្រះអង្គ-នៅសព្វថ្ងៃ សត្វមាននិស្ស័យ-ពីបុរាណ
ប្រឹងរៀនប្រឹងស្ដាប់-ចេះចាំបាន កាន់តាមលំអាន-បានក្ដីសុខ
ឥតមានសុខណា-ស្មើក្ដីស្ងប់ បញ្ចប់ត្រឹមសុខ-ឃ្លាតចាកទុក្ខ
តាំងពីលោកនេះ-តទៅមុខ ក្ដីសុខនឹងមាន-ព្រោះធម៌ស្ងប់ ។

ខ្ញុំសូមបង្គំ-ឆ្ពោះព្រះធម៌ ព្រះសង្ឃបវរ-ទាំងគ្រប់សព្វ
រួមជាត្រៃរ័ត្ន-គួរគោរព ជាម្លប់ត្រជាក់-នៃលោកា
ព្រះរូបព្រះធាតុ-នៃព្រះពុទ្ធ វិសុទ្ធតាងអង្គ-ព្រះសាស្ដា
សូមគុណត្រៃរ័ត្ន-ជួយខេមរា ឱ្យបានសុខា-តរៀងទៅ ។

(ដោយសម្ដេចព្រះមហាសុមេធាធិបតី ជួន-ណាត ជោតញ្ញាណោ)

មនុស្សល្ងង់ ទុកបេះដូងនឹងអណ្ដាត មនុស្សឆ្លាត ទុកអណ្ដាតនឹងបេះដូង ។

# ធម៌សូត្រលើកទង់ព្រះពុទ្ធសាសនា

សូមមើលទង់ជ័យឆព្វណ្ណរង្សី　　ដែលមានរស្មីដ៏ភ្លឺស្រស់ល្អ
ខៀវលឿងក្រហមព្រមទាំងពណ៌ស　　ហង្សបាទនិងពណ៌ដ៏សែនភ្លឺផ្លេក ។
ប្រទេសតូចធំបានស្ម័គ្រស្នាគម　　ជំនុំគ្នាច្រើនដ៏សែនអនេក
ព្រមយករស្មីព្រះពុទ្ធគួរត្រេក　　ប្រសើរពន់ពេកច្រើនក្រៃកន្លង ។
ធ្វើជាសញ្ញាទង់ជ័យសាសនា　　នៃព្រះសម្មាសម្ពុទ្ធធំចម្បង
ចូរយើងរាល់គ្នាយកចិត្តចងចាំ　　នឹកដល់ព្រះអង្គជាអម្ចាស់ ។
ទោះជាតិផ្សេងគ្នាក៏ត្រូវដឹងថា　　សុទ្ធសឹងតែជាព្រះពុទ្ធសាសន៍
ត្រូវមានសាមគ្គីទាំងក្មេងទាំងចាស់　　ប្រឹងប្រែងឱ្យណាស់ឱ្យគ្រប់ៗគ្នា ។
សូមសាសនាពុទ្ធថ្កុំថ្កើងបំផុត　　រុងរឿងវិសុទ្ធប្រសើរថ្លៃថ្លា
ហើយមានជោគជ័យផ្សាយពេញលោកា .ដោយជនជ្រះថ្លាមានច្រើនសែនលាន ។
មានចិត្តស្នេហាគោរពបូជា　　ចំពោះព្រះធម៌ដ៏ល្អកល្យាណ
ទាំងមនុស្សទេវតាស្នេហាគ្រប់ប្រាណ　　ប្រាថ្នាចង់បាននូវសេចក្តីសុខ ។
យើងខេមរជាតិនាំគ្នាខ្មីឃ្មាត　　កាន់ធម៌នឹងបានរួចផុតចាកទុក្ខ
រួបរួមសាមគ្គីពីនេះទៅមុខ　　យើងនឹងបានសុខក្សេមក្សាន្តត្រាណ ។

ព្រមព្រៀងប្រព្រឹត្តកាន់ធម៌សុចរិត ឆ្ពោះទៅកាន់ឋានបរមនិព្វាន
ជាទីផុតទុក្ខបានសុខក្សេមក្សាន្ត ជាតិយើងនឹងបានសុខតាមប្រាថ្នា ។

# កំណើតឆព្វណ្ណរង្សី

ជាតិយើងអ្នកកាន់សាសនា ត្រូវដឹងច្បាស់ថាព្រះពុទ្ធជិនស្រី
ទ្រង់មានឆព្វណ្ណរង្សី គឺព្រះរស្មីទាំងប្រាំមួយពណ៌ ។
ផ្សាយចេញពីព្រះកាយទ្រង់ រុងរឿងឫទ្ធិរុងប្រសើរបវរ
ឆ្សៀលឆ្លាត់កាយឆើតឆាយល្អ ទាំងប្រាំមួយពណ៌ស្រស់ល្អសោភា
។ កំណើតនៃព្រះរស្មី កើតដោយបារមីនៃព្រះភគវា
ធ្វើទានឥតមានរួញរា កាលដែលនៅជាព្រះពោធិសត្វ ។
រស្មីពណ៌ខៀវនេះណា កាលឆ្កៀលនេត្រាទ្រង់ដោយចិត្តកាត់
ធ្វើទានដល់ឥន្ទព្រាហ្មណ៍ពិត កាលនៅជាក្សត្រនាមស្រីពិរាស្ត្រ ។
រស្មីពណ៌លឿងនេះណា កាលដែលទ្រង់អារសាច់ផែធ្វើមាស
បិទពុទ្ធរូបភ្លឺល្អឱភាស ព្រះឥន្ទជាងមាសទ្រង់វៃបណ្ឌិត ។
រស្មីក្រហមនេះណា កាលដែលមាតាពស់ខាំស្លាប់ពិត
បទុមសូប្តូរជីវិត កាត់បេះដូងបិទធ្វើថ្នាំមាតា ។

រស្មីពណ៌សសុទ្ធសាធ　　　កាលដែលព្រះបាទវេស្សន្តរក្សត្រា
ឱ្យទានដំរីសសោភា　　　ដល់ព្រាហ្មណ៍ប្រាថ្នាយកពោធិញ្ញាណ ។
រស្មីពណ៌ដូចជើងហង្ស　　　កាលមាតាទ្រង់យក្សចាប់យកបាន
វិជ្ជាធរអោរសាច់ខ្លួនប្រាណ　　　ឱ្យយក្សសាមាន្យស៊ីប្តូរជីវិត ។
រស្មីភ្លឺផ្លេកពណ្ណរាយ　　　កាលជាទន្សាយឈ្មោះសោមបណ្ឌិត
ឱ្យទានសាច់ឈាមជីវិត　　　ដល់ឥន្ទ្រព្រាហ្មណ៍ពិតថាអត់អាហារ ។
រស្មីខៀវស្មើងក្រហម　　　សហង្សបាទព្រមភ្លឺផ្លេកអស្ចារ្យ
ត្រូវជាប្រាំមួយប្រការ　　　ក្មេងចាស់កុមារចូរចាំទុកអើយ ។

២៥៤-កុំយកពាលជាមិត្ត　កុំយកបណ្ឌិតជាសត្រូវ ។

២៦២-មានសត្រូវជាបណ្ឌិត　ល្អជាងមានមិត្តជាជនពាល ។

២៥៨-ស្តាប់ព្រះធម៌ច្រើនកើនបញ្ញា　សង្រួមវាចាត្រជាក់ចិត្ត ។

២៥៩-ធ្វើឱ្យគេស្រលាញ់មិនងាយទេ　　ធ្វើឱ្យគេជេរវាងាយណាស់ ។

២៩១-មានទ្រព្យមនុស្ស...រាប់អាន មានបញ្ញាញាណ...មនុស្សបូជា ។

# ព្រះពុទ្ធ ២៨ ព្រះអង្គ

នមោ មេ សព្វពុទ្ធានំ ឧប្បន្នានំ មហេសិនំ

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ ចំពោះព្រះពុទ្ធជាម្ចាស់គ្រប់ព្រះអង្គ ដែលបានត្រាស់រួចមកហើយ ព្រះអង្គស្វែងរកនូវគុណដ៏ធំ ( ព្រះសម្ពុទ្ធទាំងនោះ គឺ )

១- តណ្ហង្ករោ មហាវីរោ

ព្រះតណ្ហង្ករ ព្រះអង្គមានព្យាយាមធំ

២- មេធង្ករោ មហាយសោ

ព្រះមេធង្ករ ព្រះអង្គមានយសធំ

៣- សរណង្ករោ លោកហិតោ

ព្រះសរណង្ក ព្រះអង្គធ្វើឱ្យជាប្រយោជន៍ដល់សត្វលោក

៤- ទីបង្ករោ ជុតិន្ធរោ

ព្រះទីបង្ករ ព្រះអង្គទ្រទ្រង់នូវបញ្ញាដ៏រុងរឿង

៥- កោណ្ឌញ្ញោ ជនបាមោក្ខោ

ព្រះកោណ្ឌញ្ញៈ ព្រះអង្គជាប្រធាននៃពពួកជន

៦- មង្គលោ បុរិសាសភោ

ព្រះមង្គលៈ ព្រះអង្គជាបុរសដ៏ប្រសើរ

៧- សុមនោ សុមនោ ធីរោ

ព្រះសុមនៈ ព្រះអង្គជាអ្នកប្រាជ្ញមានព្រះហឫទ័យដ៏ល្អ

៨- រេវតោ រតិវឌ្ឍនោ

ព្រះរេវតៈ ព្រះអង្គញុំាងសេចក្តីត្រេកអរឱ្យចម្រើន

៩- សោភិតោ គុណសម្បន្នោ

ព្រះសោភិតៈ ព្រះអង្គបរិបូណ៌ដោយគុណ

១០- អនោមទស្សី ជនុត្តមោ

ព្រះអនោមទស្សី ព្រះអង្គឧត្តមជាងពពួកជន

១១- បទុមោ លោកបជ្ជោតោ

ព្រះបទុមៈ ព្រះអង្គញុំាងលោកឱ្យភ្លឺស្វាង

១២- នារទោ វរសារថី

ព្រះនារទៈ ព្រះអង្គដូចជាសារថីដ៏ប្រសើរ

១៣- បទុមុត្តរោ សត្តសារោ

ព្រះបទុមុត្តរៈ ព្រះអង្គជាខ្លឹមសារនៃពួកសត្វ

១៤- សុមេធោ អប្បដិបុគ្គលោ

ព្រះសុមេធៈ ព្រះអង្គរកបុគ្គលប្រៀបដូចគ្មាន

១៥- សុជាតោ សព្វលោកគ្គោ

ព្រះសុជាតៈ ព្រះអង្គប្រសើរលើសជាងសត្វលោកទាំងពួង

១៦- បិយទស្សី នរាសភោ

ព្រះបិយទស្សី ព្រះអង្គប្រសើរជាងនរជន

១៧- អត្ថទស្សី ការុណិកោ

ព្រះអត្ថទស្សី ព្រះអង្គប្រកបដោយករុណា

១៨- ធម្មទស្សី តមោនុទោ

ព្រះធម្មទស្សី ព្រះអង្គបន្ទោបង់នូវងងឹត

១៩- សិទ្ធត្ថោ អសមោ លោកេ

ព្រះសិទ្ធត្ថ ព្រះអង្គឥតមានអ្នកណាស្មើក្នុងលោក

២០- តិស្សោ ច វទតំ វរោ

ព្រះតិស្សៈ ព្រះអង្គប្រសើរជាងអ្នកប្រាជ្ញខាងសម្ដីទាំងឡាយ

២១- ផុស្សោ ច វរទោ ពុទ្ធោ

ព្រះពុទ្ធទ្រង់ព្រះនាមផុស្សៈ ព្រះអង្គប្រទាននូវធម៌ដ៏ប្រសើរ

២២- វិបស្សី ច អនូបមោ

ព្រះវិបស្សី ព្រះអង្គឥតមានអ្នកណាប្រៀបផ្ទឹមបានឡើយ

២៣- សិខី សព្វហិតោ សត្ថា

ព្រះសិខី ព្រះអង្គជាគ្រូប្រៀនប្រដៅ ធ្វើឱ្យជាប្រយោជន៍ដល់សត្វទាំងពួង

២៤- វេស្សភូ សុខទាយកោ

ព្រះវេស្សភូ ព្រះអង្គប្រទាននូវសេចក្តីសុខ

២៥- កកុសន្ធោ សត្ថវាហោ

ព្រះកកុសន្ធៈ ព្រះអង្គនាំសត្វចេញចាកផ្លូវឆ្ងាយដាច់ស្រយាល គឺកិលេស

២៦- កោនាគមនោ រណញ្ជហោ

ព្រះកោនាគមនៈ ព្រះអង្គបំបាត់បង់នូវសត្រូវ គឺកិលេស

២៧- កស្សបោ សិរិសម្បន្នោ

ព្រះកស្សបៈ ព្រះអង្គបរិបូណ៌ដោយសិរី

២៨- គោតមោ សក្យបុង្គវោ

ព្រះគោតម ព្រះអង្គប្រសើរចម្បងជាងពួកសក្យរាជ ។

(ស្រង់ចាក សៀវភៅជំនួយសតិ ភាគ ១៤ ទំព័រ ៦៦ )

# ឯតទគ្គបាលី-ប្រែ

(ស្រង់ចាក ព្រះសុត្តន្តបិដក ភាគ ៤០ ទំព័រ ៥៣ )

## ឯតទគ្គភិក្ខុ

[១៤៦] ១- ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ រត្តញ្ញូនំ យទិទំ អញ្ញាកោណ្ឌញ្ញោ

ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកដឹងរាត្រីដែលជាសាវ័ករបស់តថាគត ស្រេចនឹងអញ្ញាកោណ្ឌញ្ញៈ ប្រសើរជាងគេ

២- មហាបញ្ញានំ យទិទំ សារីបុត្តោ

បណ្តាពួកភិក្ខុអ្នកមានប្រាជ្ញាច្រើន ស្រេចនឹងសារីបុត្ត

៣- ឥទ្ធិមន្តានំ យទិទំ មហាមោគ្គល្លានោ

ពួកភិក្ខុអ្នកមានឫទ្ធិ ស្រេចនឹងមហាមោគ្គលាន

៤- ធុតវាទានំ យទិទំ មហាកស្សបោ

ពួកភិក្ខុអ្នកពោលពាក្យកម្ចាត់បង់កិលេស ស្រេចនឹងមហាកស្សបៈ

៥- ទិព្វចក្ខុកានំ យទិទំ អនុរុទ្ធោ

ពួកភិក្ខុអ្នកមានទិព្វចក្ខុ ស្រេចនឹងអនុរុទ្ធ

៦-ឧច្ចាកុលិកានំ យទិទំ ភទ្ទិយោ កាឡិគោធាយបុត្តោ

ពួកភិក្ខុអ្នកមានត្រកូលខ្ពស់ ស្រេចនឹងភទ្ទិយកាឡិគោធាយបុត្ត

៧- មញ្ជុស្សរានំ យទិទំ លកុណ្ឌកភទ្ទិយោ

ពួកភិក្ខុអ្នកមានសំឡេងពីរោះ ស្រេចនឹងលកុណ្ឌកភទ្ទិយៈ

៨- សីហនាទិកានំ យទិទំ បិណ្ឌោលភារទ្វាជោ

ពួកភិក្ខុអ្នកបន្លឺសីហនាទ ស្រេចនឹងបិណ្ឌោលភារទ្វាជៈ

៩- ធម្មកថិកានំ យទិទំ បុណ្ណោ មន្តានីបុត្តោ

ពួកភិក្ខុជាធម្មកថិក ស្រេចនឹងបុណ្ណមន្តានីបុត្ត

១០- សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ វិភជន្តានំ យទិទំ មហាកច្ចានោតិ

ពួកភិក្ខុអ្នកចែកសេចក្តីធម៌ ដែលតថាគត សម្តែងដោយសង្ខេបឱ្យពិស្តារបាន ស្រេចនឹងមហាកច្ចានៈ។

(វគ្គោ បឋមោ : **ចប់វគ្គទី១**)

[១៤៧] ១១- ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ មនោមយំ កាយំ អភិនិម្មិនន្តានំ យទិទំ ចុល្លបន្ថកោ

ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុអ្នកនិម្មិតកាយសម្រេចតាមចិត្តបាន ដែលជាសាវ័ករបស់ តថាគត ស្រេចនឹងចុល្លបន្ថកៈ ប្រសើរជាងគេ

១២- ចេតោវិវដ្ដកុសលានំ យទិទំ ចុល្លបន្ថកោ

ពួកភិក្ខុអ្នកឈ្លាសក្នុងការលើកចិត្ត ស្រេចនឹងចុល្លបន្ថកៈ

១៣- បញ្ញាវិវដ្ដកុសលានំ យទិទំ មហាបន្ថកោ

ពួកភិក្ខុអ្នកឈ្លាសក្នុងការលើកប្រាជ្ញា ស្រេចនឹងមហាបន្ថកៈ

១៤- អរណវិហារីនំ យទិទំ សុភូតិ

ពួកភិក្ខុអ្នកនៅដោយឥតកិលេស ស្រេចនឹងសុភូតិ

១៥- ទក្ខិណេយ្យានំ យទិទំ សុភូតិ

ពួកភិក្ខុអ្នកគួរដល់ទក្ខិណាទាន ស្រេចនឹងសុភូតិ

១៦- អារញ្ញកានំ យទិទំ រេវតោ ខទិរវនិយោ

ពួកភិក្ខុអ្នកនៅក្នុងព្រៃ ស្រេចនឹងរេវតខទិរវនិយៈ

១៧- ឈាយីនំ យទិទំ កង្ខារេវតោ

ពួកភិក្ខុអ្នកបានឈាន ស្រេចនឹងកង្ខារេវតៈ

១៨- អារទ្ធវិរិយានំ យទិទំ សោណោ កោឡិវិសោ

ពួកភិក្ខុអ្នកមានព្យាយាមបរិបូណ៌ ស្រេចនឹងសោណកោឡិវិសៈ

១៩- កល្យាណវាក្ករណានំ យទិទំ សោណោ កុដិកណ្ណោ
ពួកភិក្ខុអ្នកពោលពាក្យពីរោះ ស្រេចនឹងសោណកុដិកណ្ណៈ
២០- លាភីនំ យទិទំ សីវលី
ពួកភិក្ខុអ្នកមានលាភ ស្រេចនឹងសីវលី
២១- សទ្ធាធិមុត្តានំ យទិទំ វក្កលីតិ
ពួកភិក្ខុអ្នកមានសទ្ធាស៊ប់ ស្រេចនឹងវក្កលិ ។

(វគ្គោ ទុតិយោ : **ចប់វគ្គទី២**)

[១៤៨] ២២- ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ សិក្ខាកាមានំ យទិទំ រាហុលោ
ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកស្រឡាញ់សិក្ខា ដែលជាសាវ័ករបស់តថាគត ស្រេចនឹងរាហុល ប្រសើរជាងគេ
២៣- សទ្ធាបព្វជិតានំ យទិទំ រដ្ឋបាលោ
ពួកភិក្ខុអ្នកបួសដោយសទ្ធា ស្រេចនឹងរដ្ឋបាល
២៤- បឋមំ សលាកំ គណ្ហន្តានំ យទិទំ កុណ្ឌធានោ
ពួកភិក្ខុអ្នកចាប់ស្លាកដំបូងបង្អស់ ស្រេចនឹងកុណ្ឌធានៈ
២៥- បដិភាណវន្តានំ យទិទំ វង្គីសោ
ពួកភិក្ខុអ្នកមានបដិភាណ ស្រេចនឹងវង្គីសៈ

២៦- សមន្តបាសាទិកានំ យទិទំ ឧបសេនោ វង្គន្តបុត្តោ

ពួកភិក្ខុអ្នកមានសេចក្ដីជ្រះថ្លាគ្រប់គ្រាន់ ស្រេចនឹងឧបសេ-
នវង្គន្តបុត្ត

២៧- សេនាសនបញ្ញាបកានំ យទិទំ ទព្វោ មល្លបុត្តោ

ពួកភិក្ខុអ្នកក្រាលសេនាសនៈ ស្រេចនឹងទព្វមល្លបុត្ត

២៨- ទេវតានំ បិយមនាបានំ យទិទំ បិលិន្ទវច្ឆោ

ពួកភិក្ខុជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ទេវតាទាំងឡាយ ស្រេចនឹងបិលិន្ទវច្ឆៈ

២៩- ខិប្បាភិញ្ញានំ យទិទំ ពាហិយោ ទារុចីរិយោ

ពួកភិក្ខុអ្នកត្រាស់ដឹងរហ័ស ស្រេចនឹងពាហិយទារុចីរិយៈ

៣០- ចិត្តកថិកានំ យទិទំ កុមារកស្សបោ

ពួកភិក្ខុអ្នកចេះសម្ដីដ៏វិចិត្ត ស្រេចនឹងកុមារកស្សបៈ

៣១- បដិសម្ភិទប្បត្តានំ យទិទំ មហាកោដ្ឋិតោ

ពួកភិក្ខុអ្នកបានបដិសម្ភិទា ស្រេចនឹងមហាកោដ្ឋិតៈ ។

(វគ្គោ តតិយោ : **ចប់វគ្គទី ៣**)

[១៤៩] ៣២- ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ ពហុស្សុតានំ យទិទំ អានន្ទោ

ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកចេះដឹងច្រើន ដែលជាសាវ័ករបស់តថាគត ស្រេចនឹងអានន្ទ ប្រសើរជាងគេ

៣៣- សតិមន្តានំ យទិទំ អានន្ទោ

ពួកភិក្ខុអ្នកមានស្មារតី ស្រេចនឹងអានន្ទ

៣៤- គតិមន្តានំ យទិទំ អានន្ទោ

ពួកភិក្ខុអ្នកមានគតិ ស្រេចនឹងអានន្ទ

៣៥- ធិតិមន្តានំ យទិទំ អានន្ទោ

ពួកភិក្ខុអ្នកមានប្រាជ្ញា ស្រេចនឹងអានន្ទ

៣៦- ឧបដ្ឋាកានំ យទិទំ អានន្ទោ

ពួកភិក្ខុជាឧបដ្ឋាក ក៏ស្រេចនឹងអានន្ទដែរ

៣៧- មហាបរិសានំ យទិទំ ឧរុវេលកស្សបោ

ពួកភិក្ខុអ្នកមានបរិស័ទច្រើន ស្រេចនឹងឧរុវេលកស្សបៈ

៣៨- កុលប្បសាទកានំ យទិទំ កាឡុទាយិ

ពួកភិក្ខុអ្នកញុំាងត្រកូលឱ្យជ្រះថ្លា ស្រេចនឹងកាឡុទាយិ

៣៩- អប្បាពាធានំ យទិទំ ពក្កុលោ

ពួកភិក្ខុអ្នកគ្មានអាពាធ ស្រេចនឹងពក្កុលៈ

៤០- បុព្វេនិវាសំ អនុស្សរន្តានំ យទិទំ សោភិតោ

ពួកភិក្ខុអ្នករឭកឃើញបុព្វេនិវាស ស្រេចនឹងសោភិតៈ

៤១- វិនយធរានំ យទិទំ ឧបាលិ

ពួកភិក្ខុអ្នកទ្រទ្រង់វិន័យ ស្រេចនឹងឧបាលិ

៤២- ភិក្ខុនោវាទកានំ យទិទំ នន្ទកោ

ពួកភិក្ខុអ្នកឱ្យឱវាទភិក្ខុនី ស្រេចនឹងនន្ទកៈ

៤៣- ឥន្ទ្រិយេសុ គុត្តទ្វារានំ យទិទំ នន្ទោ

ពួកភិក្ខុអ្នករក្សាទ្វារក្នុងឥន្ទ្រិយទាំងឡាយ ស្រេចនឹងនន្ទៈ

៤៤- ភិក្ខុឱវាទកានំ យទិទំ មហាកប្បិនោ

ពួកភិក្ខុអ្នកឱ្យឱវាទភិក្ខុ ស្រេចនឹងមហាកប្បិន

៤៥- តេជោធាតុកុសលានំ យទិទំ សាគតោ

ពួកភិក្ខុអ្នកឈ្លាសវៃក្នុងតេជោធាតុ ស្រេចនឹងសាគតៈ

៤៦- បដិភាណេយ្យកានំ យទិទំ រាធោ

ពួកភិក្ខុអ្នកឈ្លាសវៃក្នុងបដិភាណ ស្រេចនឹងរាធៈ

៤៧- លូខចីវរធរានំ យទិទំ មោយរាជាតិ

ពួកភិក្ខុអ្នកទ្រទ្រង់ចីវរសៅហ្មង ស្រេចនឹងមោយរាជ ។

( វគ្គោ ចតុត្ថោ : **ចប់វគ្គទី ៤** )

# ភិក្ខុនី

[១៥០] ១- ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ភិក្ខុនីនំ

រត្តញ្ញូនំ យទិទំ មហាបជាបតី គោតមី

ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុនីអ្នកដឹងរាត្រី ដែលជាសាវិកា

របស់តថាគត ស្រេចនឹងមហាបជាបតីគោតមី ប្រសើរជាងគេ

២- មហាបញ្ញានំ យទិទំ ខេមា

ពួកភិក្ខុនីអ្នកមានប្រាជ្ញាច្រើន ស្រេចនឹងនាងខេមា

៣- ឥទ្ធិមន្តីនំ យទិទំ ឧប្បលវណ្ណា

ពួកភិក្ខុនីអ្នកមានឫទ្ធិ ស្រេចនឹងនាងឧប្បលវណ្ណា

៤- វិនយធរានំ យទិទំ បដាចារា

ពួកភិក្ខុនីអ្នកទ្រទ្រង់វិន័យ ស្រេចនឹងនាងបដាចារា

៥- ធម្មកថិកានំ យទិទំ ធម្មទិន្នា

ភិក្ខុនីជាធម្មកថិកា ស្រេចនឹងនាងធម្មទិន្នា

៦- ឈាយិនីនំ យទិទំ នន្ទា

ពួកភិក្ខុនីអ្នកមានឈាន ស្រេចនឹងនាងនន្ទា

៧- អារទ្ធវីរិយានំ យទិទំ សោណា

ពួកភិក្ខុនីអ្នកមានព្យាយាមបរិបូណ៌ ស្រេចនឹងនាងសោណា

៨- ទិព្វចក្ខុកានំ យទិទំ សកុលា

ពួកភិក្ខុនីអ្នកមានទិព្វចក្ខុ ស្រេចនឹងនាងសកុលា

៩- ខិប្បាភិញ្ញានំ យទិទំ ភទ្ទា កុណ្ឌលកេសា

ពួកភិក្ខុនីបានត្រាស់ដឹងរហ័ស ស្រេចនឹងនាងភទ្ទាកុណ្ឌលកេសា

១០- បុព្វេនិវាសំ អនុស្សរន្តីនំ យទិទំ ភទ្ទា កបិលានី

ពួកភិក្ខុនីអ្នករឭកឃើញបុព្វេនិវាស ស្រេចនឹងនាងភទ្ទាកបិលានី

១១- មហាភិញ្ញាបត្តានំ យទិទំ ភទ្ទា កច្ចានា

ពួកភិក្ខុនីអ្នកបានអភិញ្ញាដ៏ធំ ស្រេចនឹងនាងភទ្ទាកច្ចានា

១២- លូខចីវរធរានំ យទិទំ កិសាគោតមី

ពួកភិក្ខុនីអ្នកទ្រទ្រង់ចីវរដ៏សៅហ្មង ស្រេចនឹងនាងកិសាគោតមី

១៣- សទ្ធាធិមុត្តានំ យទិទំ សិគាលមាតាតិ

ពួកភិក្ខុនីអ្នកមានសទ្ធាស៊ប់ ស្រេចនឹងនាងសិគាលមាតា ។

( វគ្គោ បញ្ចមោ : **ចប់វគ្គទី ៥**)

## ឧបាសិកា

[១៥១] ១- ឯតទគ្គំ ភិក្ខវេ មម សាវកានំ

ឧបាសកានំ បឋមំ សរណំ គច្ឆន្តានំ យទិទំ

តបុស្សភល្លិកា វាណិជា

ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកឧបាសកអ្នកដល់សរណៈជាបឋម ដែលជាសាវ័ករបស់តថាគត ស្រេចនឹងតបុស្សពាណិជ និងភល្លិកពាណិជ ប្រសើរជាងគេ

២- ទាយកានំ យទិទំ សុទត្តោ គហបតិ អនាថបណ្ឌិកោ

ពួកឧបាសកជាទាយក ( អ្នកឱ្យទាន ) ស្រេចនឹងសុទត្ត - គហបតី គឺអនាថបណ្ឌិកសេដ្ឋី

៣- ធម្មកថិកានំ យទិទំ ចិត្តោ គហបតិ មច្ឆិកសណ្ឌិកោ

ពួកឧបាសកជាធម្មកថិក ស្រេចនឹងចិត្តគហបតី ដែលនៅក្នុងស្រុកមច្ឆិកសណ្ឌៈ

៤- ចតូហិ សង្គហវត្ថូហិ បរិសំ សង្គណ្ហន្តានំ យទិទំ ហត្ថកោ អាឡវកោ

ពួកឧបាសកអ្នកសង្គ្រោះបរិស័ទ ឱ្យដោយសង្គហវត្ថុ ៤ ប្រការ ស្រេចនឹងហត្ថកអាឡវកៈ

៥- បណីតទាយកានំ យទិទំ មហានាមោ សក្កោ

ពួកឧបាសកអ្នកឱ្យភោជនមានរសដ៏ឧត្ដម ស្រេចនឹងមហានាមសក្កៈ

៦- មនាបទាយកានំ យទិទំ ឧគ្គោ គហបតិ វេសាលិកោ

ពួកឧបាសកអ្នកឱ្យភោជនជាទីគាប់ចិត្ត ស្រេចនឹងឧគ្គគហ-
បតីអ្នកនៅក្នុងក្រុងវេសាលី

៧- សង្ឃុបដ្ឋាកានំ យទិទំ ឧគ្គតោ គហបតិ

ពួកឧបាសកអ្នកបម្រើសង្ឃ ស្រេចនឹងឧគ្គតគហបតី

៨- អវេច្ចប្បសន្នានំ យទិទំ សូរោ អម្ពដ្ឋោ

ពួកឧបាសកអ្នកជ្រះថ្លាមិនកម្រើក ស្រេចនឹងសូរអម្ពដ្ឋៈ

៩- បុគ្គលប្បសន្នានំ យទិទំ ជីវកោ កោមារភច្ចោ

ពួកឧបាសកអ្នកញុំាងបុគ្គលឱ្យជ្រះថ្លា ស្រេចនឹងជីវកកោមារភច្ច

១០- វិស្សាសកានំ យទិទំ នកុលបិតា គហបតីតិ

ពួកឧបាសកអ្នកចេះនិយាយឱ្យអ្នកដទៃស្និទ្ធស្នាល ស្រេច
នឹងនកុលបិតាគហបតី ។

(វគ្គោ ឆដ្ឋោ : **ចប់វគ្គទី ៦**)

# ឧបាសិកា

[១៥២] ១- ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ឧបា-
សិកានំ បឋមំ សរណំ គច្ឆន្តីនំ យទិទំ សុជាតា
សេនានិធីតា

ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកឧបាសិកា អ្នកដល់នូវសរណៈជាបឋម ដែលជាសាវិការបស់តថាគត ស្រេចនឹងនាងសុជាតា សេនានិធីតា ប្រសើរជាងគេ

២- ទាយិកានំ យទិទំ វិសាខា មិគារមាតា

ពួកឧបាសិកាជាទាយិកា ( អ្នកឱ្យទាន ) ស្រេចនឹងនាងវិសាខា មិគារមាតា

៣- ពហុស្សុតានំ យទិទំ ខុជ្ជុត្តរា

ពួកឧបាសិកាអ្នកចេះដឹងច្រើន ស្រេចនឹងនាងខុជ្ជុត្តរា

៤- មេត្តាវិហារីនំ យទិទំ សាមាវតី

ពួកឧបាសិកាអ្នកនៅដោយមេត្តា ស្រេចនឹងនាងសាមាវតី

៥- ឈាយីនំ យទិទំ ឧត្តរា នន្ទមាតា

ពួកឧបាសិកាអ្នកមានឈាន ស្រេចនឹងនាងឧត្តរានន្ទមាតា

៦- បណីតទាយិកានំ យទិទំ សុប្បវាសា កោលិយធីតា
ពួកឧបាសិកាអ្នកឱ្យទានធ្ងិតធ្ងង់ ស្រេចនឹងនាងសុប្បវាសាកោលិយធីតា
៧- គិលានុបដ្ឋាកីនំ យទិទំ សុប្បិយា ឧបាសិកា
ពួកឧបាសិកាអ្នកបម្រើជំងឺ ស្រេចនឹងនាងសុប្បិយាឧបាសិកា
៨- អវេច្ចប្បសន្នានំ យទិទំ កាតិយានី
ពួកឧបាសិកាអ្នកជ្រះថ្លាមិនកម្រើក ស្រេចនឹងនាងកាតិយានី
៩- វិស្សាសិកានំ យទិទំ នកុលមាតាគហបតានី
ពួកឧបាសិកាអ្នកចេះធ្វើឱ្យអ្នកដទៃស្និទ្ធស្នាល ស្រេចនឹងនាងនកុលមាតាគហបតានី
១០- អនុស្សវប្បសន្នានំ យទិទំ កាលិ ឧបាសិកា កុររឃរិកាតិ
ពួកឧបាសិកាអ្នកជ្រះថ្លាតាមពាក្យដែលឮត ៗ គ្នា ស្រេចនឹងនាងកាលី ឧបាសិកាកុររឃរិកា ( កុលឃរិកា ) ។

(វគ្គោ សត្តមោ : **ចប់វគ្គទី ៧**)

# ធម្មនិយាម ៣០

## របស់ព្រះពុទ្ធគ្រប់ព្រះអង្គ

សូមក្រាបបង្គំប្រណម្យវន្ទា　　ឆ្ពោះព្រះភគវាពុទ្ធាបានត្រាស់
ធម្មនិយាមទំនៀមល្អល្អះ　　សាមសិបមុខច្បាស់ខ្ញុំសូមពណ៌នា ។
មួយរព្ឈយភពជាតិគ្រប់ចុងក្រោយ　　បារមីនាំឱ្យដឹងពេលវេលា
ទ្រង់យាងកាន់ផ្ទៃស្មារតីល្អជា　　ដឹងខ្លួនគ្រប់គ្រាក្នុងគភ៌មាតា ។
ពីរគឺព្រះភក្ត្រវរលក្ខណ៍ក្នុងគភ៌　　ស្ថិតស្ថាធិ៍ក្នុងធម៌បវរកាយា
ព្រះភក្ត្របែរផ្ទុយពីខ្នងមាតា　　ឆ្ពោះផ្ទៃភ្លឺថ្លាមាតាំរំពៃ ។
បីឥរិយាបថនៃព្រះមាតា　　ពេលគ្រប់មាសាសាស្តាចាកផ្ទៃ
មាតាទ្រង់ឈរខុសស្រីដទៃ　　ប្រសូតបុត្រថ្ងៃឃប្ចទ័យជ្រះថ្លា ។
បួនសួនឧទ្យានទីឋានប្រសូត　　ក្នុងព្រៃឃ្លួតឈើស្រួតចេញផ្កា
ទេវតានិងមនុស្សថ្វាយសាធុការ　　ចក្រវាលបព្វតាខ្ទរខ្ទារអ៊ូអរ ។
ប្រាំព្រះប្រសូតចុះស្រួតយាងឈាន　　ប្រាំពីរជំហានឆ្ពោះទិសឧត្តរ
ត្រួតគ្រប់ទិសឋានក្លាហានបវរ　　ទើបបានបន្លឺសីហនាទ ។
ប្រាំមួយប្រមើលទតមើលនិមិត្ត　　ទេវទូតបួនពិតចិត្តគិតលះញាតិ
បុត្រកើតថ្ងៃណាថ្ងៃនោះទ្រង់ឃ្លាត　　ចិត្តឥតរវាតយាត្រាសាងផ្នួស ។

ប្រាំពីរធីរោផ្តាច់ប្តូរព្យាយាម ឥតមានទាក់ទាមក្នុងនាមអ្នកបួស
កំណត់វេលាមិនអាចតិចឃ្លួស ប្រាំពីរថ្ងៃនោះនឹងបានត្រាស់ដឹង ។
ប្រាំបីមហេសីគង់សោយបាយាស ក្នុងថ្ងៃបានត្រាស់ទ្រង់ច្បាស់ទីពឹង
បាយាសថាសមាសថ្វាយព្រះថ្ងៃហ្នឹង ហៅបាយត្រាស់ដឹងបានបុណ្យមហិមា ។
ប្រាំបួនជូនភព្វ័ទ្រង់ទ្រាប់ស្បូវភ្លាំង ក្លាយជាបល្ល័ង្កគង់តាំងភាវនា
នៅគល់ពោធិព្រឹក្សនាទិសបូព៌ា បល្ល័ង្កភគវាផុសគ្រាសាយ័ណ្ហ ។
ដប់គាប់ហេបូទ័យអានាបាណៈ បរិកម្មប្រចក្សសតិដឹងទាន់
ខ្យល់ចេញខ្យល់ចូលចិត្តមូលមិនភាន់ ដំណើរជវ័នជាន់ឆ្លងកាមា ។
ដប់មួយជំនួយពីព្រះបារមី ផ្ចាញ់មារអប្រីយ៍ព្រមទាំងសេនា
ពុទ្ធប្បវត្តិត្រង់នេះអស្ចារ្យ បរិស័ទជ្រះថ្លាបាចផ្កាអភិសេក ។
ដប់ពីរមុនីអង្គទ្រង់សម្រេចញាណ ត្រៃវិជ្ជាមានទ្រង់ញាណអនេក
ពិសាខបុណ្ណមីកើតញាណប្លែកៗ ពោធិញ្ញាណខ្ពស់ឯកកក្រើកធរណី ។
ដប់បីក្សត្រថ្លៃគង់ក្នុងមហាឋាន វិមុត្តិក្សេមក្សាន្តអស់ឋានប្រាំពីរ
សប្តាហ៍ឋានមួយលើកស្ទួយស្ថានទី ចេតិយព្រះមុនីប្រាំពីរកន្លែង ។
ដប់បួនជូនព្រហ្មជុំអារាធនា សូមព្រះភគវាយាងត្រាស់សម្តែង
ព្រះធម៌ប្រពៃវិស័យសូរ្យសែង ទ្រង់ព្រមសម្តែងដោយព្រហ្មវិហារ ។

ដប់ប្រាំចាំច្បាស់ទ្រង់ត្រាស់ធម្មចក្ក ឥសិបតនៈព្រៃមិគទាយា
ឋានត្រៃរតនៈអាសាឡ្ហ បូជា ថ្ងៃព្រះភគវាស្ថាបនាព្រះសង្ឃ ។
ដប់ប្រាំមួយទ្រង់គង់ត្រាស់ឱវាទ បាតិមោក្ខស្អាងស្អាតឱវាទផ្លូវផង់
បេះដូងព្រះធម៌ពន្លឺចតុរង្គ ថ្ងៃនោះត្រូវត្រង់មាឃបុណ្ណមី ។
ដប់ប្រាំពីរទ្រង់គង់វត្តជេតពន ប្រោសដល់មហាជននិរន្តរ៍ប្រក្រតី
ទ្រង់យកអរុណជេតពនសួស្ដី ជេតពនជិនស្រីអាស្រ័យជានិច្ច ។
ដប់ប្រាំបីទ្រង់សម្ដែងបាដិហារ្យ យមកៈអស្ចារ្យនិគ្រន្ថរត់គេច
នៅក្រុងសាវត្ថីប្រុសស្រីមិនតិច នេះគឺពុទ្ធកិច្ចសង្គ្រោះលោកា ។
ដប់ប្រាំបួនទ្រង់គង់ឋានត្រៃត្រិង្ស ត្រិះរិះរំពឹងថ្លឹងគុណមាតា
សម្ដែងអភិធម្មស័ក្តិសមអស្ចារ្យ ថ្វាយព្រះមាតាសុខាអមតៈ ។
ម្ភៃគឺព្រះអង្គទ្រង់ចាកទេវលោក ស្ដេចយាងចុះមកដែនសង្កស្សៈ
មហាជនច្រើនពិតយកចិត្តទុកដាក់ បូជាគារវៈអចលចេតិយ ។
ម្ភៃមួយគឺទ្រង់គង់ក្នុងសមាបត្តិ ព្រះញាណស្ងប់ស្ងាត់លះកាត់លោកីយ៍
អរហត្តផលតម្កល់ប្រក្រតី ឆាប់ក្ដីយូរក្ដីវិស័យពុទ្ធញ្ញាណ ។
ម្ភៃពីរប្រមើលមើលគ្រប់វេនេយ្យ ឧបនិស្ស័យសព្វសត្វដែលមាន
ដោយព្រះករុណាសមាបត្តិញ្ញាណ ត្រួតសត្វកោដិលានមានពីរវារៈ ។

ម្ភៃបីទ្រង់លៃវិន័យអាជ្ញា បញ្ញត្តសិក្ខាតាមការជ្រាបជាក់
មានរឿងកើតមុនខូចគុណសាវ័ក មានហេតុជាក់លាក់ទើបដាក់វិន័យ ។
ម្ភៃបួនអង្រ្គួនបច្ច័យករុណា ជាតកទេសនាសាស្តាលកលៃ
ដើមរឿងជាហេតុបង្កើតអត្ថន័យ ជាតកប្រពៃលៃតាមហេតុការណ៍ ។
ម្ភៃប្រាំទ្រង់ប្រាសដល់ពួកព្រះញាតិ អង្គព្រះលោកនាថសម្តែងបាដិហារ្យ
កម្ចាត់មានះព្រះញាតិវង្សា ទើបត្រាស់ទេសនាគម្ពីរពុទ្ធវង្ស ។
ម្ភៃប្រាំមួយទ្រង់គង់ធ្ងន់ក្នុងធម៌ បរិស័ទណាល្អមានធម៌ទ្រទ្រង់
ស្តេចយាងទទួលស្រុះស្រួលដោយអង្គ គារវៈធ្ងូរផង់ផ្គោះត្រង់ព្រះធម៌ ។
ម្ភៃប្រាំពីរទ្រង់គង់ចាំព្រះវស្សា
ឃើមាននរណានិមន្តដោយល្អ ពេលចេញវស្សាមុនយាងចេញចរ
ទ្រង់ចម្រើនពរត្រាស់លាអ្នកនោះ ។ ម្ភៃប្រាំបីទ្រង់គង់យ៉ាងល្អត់ចត់
មុនភត្តក្រោយភត្តគ្មានភ្លាត់ភ្លេចសោះ
បំពេញពុទ្ធកិច្ចគ្រប់យាមទាំងអស់ ពុទ្ធកិច្ចសង្គ្រោះមនុស្សនិងទេវតា ។
ម្ភៃប្រាំបួនទ្រង់គង់សោយមំសៈ ក្នុងថ្ងៃទ្រង់ដាក់អនុដ្ឋានកាយា
បិណ្ឌបាតចុងក្រោយជាទានថ្លៃថ្លា សោយរសមំសាបច្ច័យបរិសុទ្ធ ។
សាមសិបអវសានទ្រង់បានចូលឈាន មុននឹងនិព្វានឈានច្រើនបំផុត

ម្ភៃបួនសែនកោដិសមាបត្តិបរិសុទ្ធ     រួចហើយទ្រង់ផុតរលត់សង្ខារ ។
អហំរីខ្ញុំបង្គំវន្ទា     ឈ្មោះព្រះភគវាព្រះធម៌ថ្លៃថ្លា
ព្រមទាំងព្រះសង្ឃផ្ទូរផង់សីលា     ចិន្តាលំអុតព្រះពុទ្ធនិយាម ។
សូមឱ្យសព្វសត្វបដិបត្តិតាមធម៌     សាសនាបវរល្អដូចព្រះនាម
អរហំសម្មាគ្មានការទាក់ទាម     កិលេសរវាមរវាតសូន្យបង់ ។
សូមឱ្យសាសនាសម្មាសម្ពុទ្ធ     បរិស័ទមោះមុតរួមចិត្តទ្រទ្រង់
ឋិតថេរចិរកាលអភិបាលដោយសង្ឃ ព្រមព្រៀងស្មោះត្រង់ផ្ចិតផ្ចង់សិក្ខា ។
សូមមនុស្សទេវតាមានការគោរព     ទាំងថ្ងៃទាំងយប់ក្នុងព្រះសាសនា
សូមបានសម្រេចដូចក្តីប្រាថ្នា     អស់នូវតណ្ហាទុក្ខាចប់ឃោង ។

( ស្រង់ចាក សៀវភៅជំនួយសតិ ភាគទី ១៤ ទំព័រ ៣១៣ )

# រក្សាព្រះត្រៃបិដក

សិក្សាបិដកមតិកព្រះ　　មានជ័យជម្នះឈ្នះមោហា
គឺជាកុសលផ្តល់បញ្ញា　　ឆ្លងវដ្តសង្សារឆ្ពោះនិព្វាន ។
ដូច្នេះយើងត្រូវថែរក្សា　　បិដកថ្លៃថ្លាជាធម្មទាន
ព្រះធម្មចេតិយប្រាជ្ញាញាណ　　សាស្តានៅមានយើងត្រូវប្រឹង ។
រក្សាបិដកមានគុណក្រៃ　　លក់លៃបែងចែកញែកឱ្យដឹង
ប្រាំពីរប្រការគិតជញ្ជឹង　　ល្អម្លឹងប្រឹងថែខ្មែរមានធម៌ ។
មួយគឺរក្សាព្រះសាសនា　　មតិកអស្ចារ្យជាពុទ្ធពរ
ពាក្យពិតពាក្យពុទ្ធសុទ្ធបវរ　　ចេតិយព្រះធម៌ វិ.សុ.អ. ។
ពីរគឺរក្សាព្រះសាស្តា　　វិន័យធម៌អាថ៌ចារទុកដាក់
ឋិតនៅជាគ្រូដ៏សមស័ក្តិ　　ប្រចក្សធម្មាជាសាស្តា ។
បីគឺរក្សាការងារសង្ឃ　　ទ្រទ្រង់តម្រង់ព្រះសាសនា
សង្គាយនាធម៌វិន័យណា　　ត្រាស់អស់វស្សាសែសិបប្រាំ ។
បួនគឺរក្សាគុណសម្បត្តិ　　នៃពុទ្ធបរស័ទចាត់ជាឆ្នាំ
ព្រះធម្មវិន័យព្រះអង្គផ្តាំ　　ឋិតច្រើនពាន់ឆ្នាំព្រោះបរិស័ទ ។

ប្រាំគឺរក្សាត្រៃសទ្ធម្ម បរិយត្តិនាំចំបដិបត្តិ
បដិវេធៈជាក់កម្ចាត់ កិលេសបង់បាត់ស្ងាត់សន្ដាន ។
ប្រាំមួយរក្សាត្រៃរតនៈ ឋិតនៅប្រចក្សសរណដ្ឋាន
ព្រះពុទ្ធព្រះធម៌នាំសុខសាន្ដ ព្រះសង្ឃកល្យាណមានវិន័យ ។
ប្រាំពីររក្សាត្រៃសិក្ខា សាសនាចារជាប់ដួងហឫទ័យ
សីលសមាធិធម៌ប្រពៃ ផុតភ័យអាស្រ័យដោយបញ្ញា ។
ព្រះត្រៃបិដកមានប្រវត្តិ រឿងរ៉ាវបានកត់ចារអក្ខរា
អរិយធម៌វប្បធម៌មនុស្សទេវតា បុណ្យយ៉ាងណាចារឱ្យដឹង ។
បិដកជាច្បាប់ប្រាប់ភពត្រ័យ អ្នកមាននិស្ស័យលៃលកប្រឹង
សិក្សាបដិបត្តិកម្ចាត់ខឹង ជញ្ជីងសម្លឹងដឹងត្រៃលក្ខណ៍ ។
បិដកច្បាប់ដើមព្រះសាសនា បាលីអក្ខរាសាស្ដាជាក់
បដិបត្តិបូជាធានាមគ្គ កំណត់ត្រៃលក្ខណ៍លាត្រៃលោក ។
កសាងចេតិយបិដកខ្មែរ យើងនាំគ្នាហែព្រះមានជោគ
សាធុ ! សាធុ ! ផុតចាករោគ សាធុផុតលោកអនុមោទនា ។

( ស្រង់ចាក សៀវភៅបទពិចារណា ទំព័រ ១២៧ )

# ខ្ញុំនឹកព្រះណាស់

ខ្ញុំឈរកណ្ដាលទីក្រុងចាស់ ខ្ញុំនឹកព្រះណាស់ពេលព្រលប់
បញ្ចូគីរីនៅឃើញគ្រប់ ចិត្តខ្ញុំប្រាថ្នាព្រះសាស្ដា ។
ផល្គុនខ្មៅតចាស់ចន្ទ្រភ្លឺហើយ ខ្ញុំពុំឃើញឡើយព្រះបិតា
បាត់ស្ងាត់សូន្យអស់អរហន្តា សល់តែសិលានិងព្រៃភ្នំ ។
ឃាក់ដូចថ្មីៗឥឡូវសោះ ស្រាប់តែបាត់អស់ចាកចោលខ្ញុំ
ខ្ញុំបានត្រឹមតែថ្វាយបង្គំ ដួងចិត្តស្រែកយំនឹកសាស្ដា ។
នឹកអើយសែននឹកអង្គព្រះពុទ្ធ ខ្ញុំសូមលំអុតឱនសិរសា
សម្ដែងរៀបរាប់ចារអក្ខរា មគធៈសាស្ដាធ្លាប់អាស្រ័យ ។
ថ្វីត្បិតរូបកាយស្ដេចឃាងបាត់ ធម្មកាយមិនខ្ចាត់ឋិតសព្វថ្ងៃ
អារាធនាអង្គព្រះពុទ្ធថ្លៃ គង់ក្នុងហឫទ័យនៃយើងខ្ញុំ ។

( ស្រង់ចាក សៀវភៅជំនួយសតិ ភាគទី ១៤ ទំព័រ ១៥៣ )

២៩៦-វិជ្ជាផ្លូវលោករៀនមិនចប់ វិជ្ជាចេះគ្រប់គឺចេះធម៌
វិជ្ជាផ្លូវលោកនៅញាប់ញ័រ វិជ្ជាផ្លូវធម៌គ្រប់ក្នុងខ្លួន ។

# កណ្ដាលទីក្រុងចាស់

(មិនមែនជាចំណងជើងធំទេ)

កណ្ដាលទីក្រុងចាស់ មើលឃើញច្បាស់ភ្នំជុំវិញ
នឹកព្រះខំបំពេញ ធម៌ដើរចេញចាកលោកា ។
ដើរតាមស្នាមព្រះបាទ ព្រះលោកនាថជាសាស្ដា
ព្រមទាំងអរហន្ដា ចាកលោកាចូលនិព្វាន ។
លោកនេះមិនគួរនៅ សុទ្ធសត្រូវតែងរុករាន
ព្រះនាំទៅនិព្វាន សត្វកោដិលានចេញចាកឋាន ។
ឥឡូវទៅអស់ហើយ គឺនៅឡើយតែលំអាន
មិនយូរនឹងបាត់ដាន ផ្លូវនិព្វានគ្មានអ្នកដើរ ។
កាលនោះដែនមគធៈ សុទ្ធអរិយៈអ្នកប្រសើរ
ឥឡូវចេញដំណើរ ដើរទៅបាត់ស្ងាត់អស់ហើយ ។

( ស្រង់ចាក សៀវភៅជំនួយសតិ ភាគទី ១៤ ទំព័រ ១៩៩ )

៣៧៤-សច្ចៈជាមរតកសំខាន់ណាស់ អ្នកដែលយល់ច្បាស់រមែងរក្សា ។

# កំណាព្យនមស្ការ សត្តមហាឋាន

ខ្ញុំសូមបង្គំប្រណម្យវន្ទា　　ឋានព្រះភគវានានាឆ្ងាយជិត
ឋានធំប្រាំពីរព្រះមុនីនៃបនិត្យ　　ឋានមួយទ្រង់ឋិតពិតមួយសប្តាហ៍ ។
សត្តមហាឋានមហាចេតិយ　　ពួកជនប្រុសស្រីគប្បីជ្រះថ្លា
ជាឋានបូជានៃមនុស្សទេវតា　　ឋិតនៅអស្ចារ្យក្នុងជម្ពូទ្វីប ។
បឋមំ　ពោធិបល្លង្កំ　　ទ្រង់តាំងបធានគ្មានស្តាយជន្មជីព
ត្រាស់ជាព្រះពុទ្ធដុតភ្លើងប្រទីប　　មនុស្សជម្ពូទ្វីបមានលាភថ្លៃថ្លា ។
ទុតិយំ　អនិមិសកំ　　ទ្រង់តាំងកាយឈរទិសបូព៌ឧត្តរា
នៃព្រះពោធិព្រឹក្សមិនព្រិចនេត្រា　　ទ្រង់ទតវិចារណ៍មហាឋានពុទ្ធោ ។
តតិយំ　ចង្កមំ　សេដ្ឋំ　　ទ្រង់តាំងហប្ញទ័យក្នុងព្រៃព្រះពោធិ៍
ទ្រង់យាងទៅមកពីទីទ្រង់ឈរ　　និងគល់ព្រះពោធិ៍ប្រពៃអស្ចារ្យ ។
ចតុត្ថំ .រតនឃរំ　　ទ្រង់តាំងពលំកម្លាំងប្រាជ្ញា
ពុះញែកអភិធម្មក្នុងផ្ទះរតនា　　ពាយ័ព្យទិសានៃទីត្រាស់ដឹង ។
បញ្ចមំ　អជបាលញ្ចំ　　ទ្រង់តាំងទ្រង់ដាក់ហប្ញទ័យនឹងធឹង
នៅទីទទួលបាយាសត្រាស់ដឹង　　ខាងកើតផងស្មឹងនេរញ្ជរា ។
មុចលិន្ទេនឆដ្ឋមំ　　ទ្រង់តាំងបល្ល័ង្កគង់ក្នុងធម្មា

ខាងត្បូងព្រះពោធិ៍មាននាគរាជា    បាំងព្រះភគវាការពារពិរុណ ។
សត្តមំ  រាជាយតនំ    ទ្រង់តាំងធម្ម៌ខ្លាំងក្លាដោយគុណ
ខាងត្បូងមុច្ចលិន្ទព្រះឥន្ទចុះមុន  បូជាព្រះគុណគង់ក្រោមដើមកែស ។
សត្តមហាឋានមហាចេតិយ    សូត្រសៀងរាល់ថ្ងៃចម្រើនចំណោះ
ចម្រើនចិត្តស្ងប់រស់មិនប្រហែស    កាត់បង់កិលេសមានះឫស្យា ។
ព្រះពុទ្ធត្រាស់ដឹងទីពឹងក្នុងលោក    ផុតពីទុក្ខសោករាគរោគតណ្ហា
គង់ក្នុងឋានស្ងាត់ប្រាំពីរសប្តាហ៍    ចេតិយសម្មាសម្ពុទ្ធគ្រប់អង្គ ។
សាធុ ! សាធុ ! សាធុ !

( ស្រង់ចាក សៀវភៅជំនួយសតិ ភាគទី ១៤ ទំព័រ ១០៧ )

៣៨០-ទឹកស្រក់តក់ៗ ទម្លុះថ្ម  រលកតៗ ថ្មសឹកដាច់
កាន់ការងារអ្វីត្រូវប្តូរផ្តាច់  ផលល្អសម្រេចព្រោះព្យាយាម ។
៣៧៩-មើលសត្វកណ្តៀរកពូនដី  មើលសត្វបក្សីក្រងសម្បុក
មើលឃ្មុំជាដើមសាងក្តីសុខ  ព្យាយាមសម្រុកបានសម្រេច ។
៣៧៦- មនុស្សយកសម្តីដំរីយកភ្លុក  ខ្មែរចងក្រងទុកជាពាក្យប្រដៅ
នាងនួនខ្លឹមក្នុងឫស្សីខ្លឹមក្រៅ  ខ្លឹមមនុស្សសំដៅនៅត្រង់ពោលពិត ។

# ថានត្រៃរតនៈ

ក្រុងពារាណសីទឹកដីពោធិសត្វ　　ក្នុងសង្សារវដ្តបំពេញបារមី
ព្រះបាទព្រហ្មទត្តគ្រងដែនកាសី　　ព្រះពោធិសត្វថ្លៃបួសជាតាបស ។
ឥសិបតនៈព្រៃមិគទាយា　　ថានព្រះភគវាគ្រប់អង្គទាំងអស់
សម្តែងធម្មចក្កប្រោសពួកតាបស　　អរិយមគ្គខ្ពង់ខ្ពស់បឋមទេសនា ។
អាសាឡបុណ្ណមីថ្ងៃកំណើតធម៌　　ទេសនាបវរមជ្ឈិមាយាត្រា
ថ្ងៃខួបកំណើតព្រះធម៌ទេសនា　　បរិស័ទជ្រះថ្លាថ្វាយផ្កាចេតិយ ។
អាសាឡបុណ្ណមីថ្ងៃកំណើតសង្ឃ　　សរណៈពេញអង្គសង្ឃគម្រប់បី
ថានត្រៃរតនៈក្នុងដែនកាសី　　អាសាឡបុណ្ណមីអាសាឡ្ហបូជា ។
ចេតិយព្រះយសខ្ពស់ព្រោះសសរ　　យសបានស្តាប់ធម៌តលំដាប់គ្នា
ឯហិភិក្ខុដោយព្រះភគវា　　ព្រះយសបានជាសង្ឃព្រះអរហន្ត ។
ហាសិបបួនអង្គសម្លាញ់ព្រះយស　　មកបួសទាំងអស់ព្រៃមិគទាយវ័ន
ថានត្រៃរតនៈថានព្រះភគវន្ត ត្រាស់ប្រាប់អរហន្តចេញផ្សាយសាសនា ។
ខ្ញុំថ្វាយបង្គំថានត្រៃរតនៈ　　ដោយចិត្តស្មោះស្ម័គ្រនឹកព្រះសាស្តា
នឹកព្រះអរហន្តនឹកធម៌ទេសនា　　ខ្ញុំសូមប្រាថ្នាផុតកាមលោកីយ៍ ។

( ស្រង់ចាក សៀវភៅជំនួយសតិ ភាគទី ១៤ ទំព័រ ៧០ )

# កុសិនារា

ខ្ញុំសូមរៀបរាប់ហេតុបីប្រការ　　ដែលព្រះសាស្ដាយាងមកនិព្វាន
នៅកុសិនារាសាស្ដាទ្រង់ញាណ　　នូវហេតុដែលមានទាំងបីប្រការ ។
ទីមួយព្រះមហាសុទស្សន-　　សូត្រមានស្ដេចក្រុងរឿងរស្មារ្យ
មានរាជធានីនៅកុសិនារា　　កាលនោះឈ្មោះថាកុសាវតី ។
ជនច្រើនបានស្ដាប់ព្រះសូត្រនេះហើយ　　មិននៅកន្តើយហើយខំខ្មីឃ្មាត
បំពេញកុសលនៅដោយស្មារតី　　ឃើញថាអ្វីៗសុទ្ធអនិច្ចា ។
ទីពីរព្រះប្រោសនាយសុភទ្ទៈ　　ដែលជាសាវ័កអាស្រ័យសាស្ដា
ព្រះអង្គទ្រង់ប្រោសប្រទានន័យថា ក្រៅព្រះសាសនាមិនមានសមណៈ ។
សុភទ្ទស្ដាប់ហើយរកត្រើយនិព្វាន　　សាស្ដានៅមានបួសជាសាវ័ក
ព្យាយាមសម្រេចអរហត្តមគ្គ　　បច្ឆិមសាវ័កនាមសុភទ្ទោ ។
ទីបីព្រោះហេតុចែកនូវព្រះធាតុ　　កុំឱ្យវិវាទដល់ថ្នាក់ឈាមឈ្ងួរ
គឺបានទោណព្រាហ្មណ៍ដែលធ្លាប់ជាគ្រូ　　ខំប្រឹងតស៊ូពោលពីខន្តី ។
សូមអ្នកទាំងឡាយរីករាយរកគ្នា　　ធាតុព្រះភគវាចែកជាប្រាំបី
ព្រះពុទ្ធបរមគ្រូសរសើរខន្តី　　ឈ្លោះគ្នាធ្វើអ្វីចែកគ្នាទើបល្អ ។
ឱកុសិនារាសាលព្រឹក្សឧទ្យាន　　ឋានព្រះទ្រង់ញាណនិព្វានពិតឆ្នាំ

នៅតែព្រះធម៌ឱ្យសត្វនិករ    ដើរតាមផ្លូវល្អតាមស្នាមព្រះបាទ ។

( ស្រង់ចាក សៀវភៅជំនួយសតិ ភាគទី ១៤ ទំព័រ ២៧៥ )

# វិសាខបុណ្ណមី

វិសាខបុណ្ណមីគឺថ្ងៃវិសេស    យើងបានចាំចេះថ្ងៃព្រះភគវា<br>
ប្រាំពីរប្រការជ្រះថ្លាវន្ទា    វិសាខបូជាប្ញក្សពារសែនល្អ ។<br>
ទីមួយគឺថ្ងៃសុមេធបណ្ឌិត    ពោធិសត្វពិតមានឫទ្ធិបវរ<br>
ចាប់ផ្ដើមទទួលព្រះពុទ្ធព្យាករណ៍    លោកធាតុញាប់ញ័រសាទរពេកក្រៃ ។<br>
ទីពីរគឺថ្ងៃក្សត្រថ្ងៃប្រសូត    អស្ចារ្យឃ្លូតសម្ភោធព្រឹក្សព្រៃ<br>
កំណើតចុងក្រោយជាប់ដោយអត្ថន័យ ផុតចាកភពត្រៃលែងភ័យលែងព្រួយ ។<br>
ទីបីគឺថ្ងៃព្រះស្រីមហាពោធិ៍    ដុះចេញលេចធ្លោពោធិ៍ពិតមានត្រួយ<br>
ថ្ងៃព្រះប្រសូតស្រួតដុះជាមួយ    ជំនួយឱ្យចិត្តបរិស័ទជ្រះថ្លា ។<br>
ទីបួនគឺថ្ងៃចមត្រៃត្រាស់ដឹង    ថ្ងៃមានទីពឹងពំនឹងលោកា<br>
ជាថ្ងៃព្រះពុទ្ធបរិសុទ្ធអស្ចារ្យ    ពួកជនជ្រះថ្លាចិន្ដាល្អស្អាត ។<br>
ទីប្រាំគឺថ្ងៃអង្គថ្ងៃនិព្វាន    ថ្ងៃព្រះទ្រង់ញាណមានពុទ្ធោវាទ<br>
បច្ឆិមវាចាថាកុំប្រមាទ    ឱវាទពិសិដ្ឋឋិតនៅជាគ្រូ ។<br>
ទីប្រាំមួយគឺថ្ងៃប្រល័យព្រះធាតុ    ចេតិយលោកនាថនៅទៀតមិនយូរ

ព្រះធាតុទាំងអស់ហោះមកគល់ពោធិ៍ តេជោរំលាយរលត់ពុទ្ធសាសន៍ ។
ប្រាំពីរគឺថ្ងៃជោគជ័យពុទ្ធា គ្រប់ព្រះភគវាឈ្នះមារបានត្រាស់
នាំមកនូវសុខវិសេសខ្លាំងណាស់ គ្រប់អង្គទ្រង់ត្រាស់ព្រះធម៌ទេសនា ។
វិសាខបុណ្ណមីថ្ងៃប្រពៃពិត យើងខ្ញុំមានចិត្តនឹងធឹងជ្រះថ្លា
វន្ទាសំពះអង្គព្រះសាស្តា សូមឲ្យធម៌ថ្វាយផ្កាបូជាប្រទីប ។
( ស្រង់ចាក សៀវភៅបទពិចារណា ទំព័រ ៦៧ )

# អដ្ឋមហាដ្ឋាន

ឋានធំទាំងឡាយ-ប្រាំបីកន្លែង ជាទីស្ងប់ស្ងែង-ដល់ពពួកសត្វ
ទីមួយឧទ្យាន-ជាឋានព្រៃស្ងាត់ គឺព្រៃសាលរត័ន៍-ដែលទ្រង់ប្រសូត ។
ទីពីរប្រសើរ-ដែលព្រះទ្រង់ស្រូត ត្រាស់ក្រោមដើម-ពោធិព្រឹក្សឧត្តម
ទីបីកន្លែង-ដែលព្រះបរម សម្តែងព្រះធម៌-ឈ្មោះធម្មចក្ក ។
ប្រោសភិក្ខុប្រាំអង្គ-គឺពួកបញ្ចវ គ្គីយ៍ដែលជាអ្នក-បម្រើព្រះអង្គ
ដោយព្រះទ័យថ្លៃ-មិនអាចលះបង់ ហើយយាងតម្រង់-ពីដើមជ្រៃទៅ ។
ទីបួនគឺទី-ដែលទ្រង់គង់នៅ ក្នុងឋានព្រៃជ្រៅ-ឈ្មោះបាលិលេយ្យ
ទីនោះគ្មានមនុស្ស-មានតែសត្វព្រៃ គឺដំរីថ្លៃ-បម្រើព្រះអង្គ ។
ទីប្រាំគឺទី-ដែលព្រះពុទ្ធអង្គ ផ្ចាញ់សត្វទ្រនង់-នាឡាគិរី

ពេលនោះមានមនុស្ស-បែកពួកជាពីរ ទៅមើលពិធី-នៃព្រះសម្ពុទ្ធ ។
ទីប្រាំមួយកាលអង្គ-ព្រះសព្វញ្ញុត ញ្ញាណជាមកុដ-នៃត្រៃលោកាចារ្យ
ទ្រង់ផ្ចាញ់និគ្រន្ថ-ដោយធ្វើបាដិហារិយ៍. ល្បីល្បាញអស្ចារ្យ-គ្មាននរណាផ្ទឹម ។
ទីប្រាំពីរកាលអង្គ-ព្រះទសពល គង់លើមណ្ឌល-ថ្មព្រះឥន្ទ្រា
ទ្រង់បានសម្តែង-នូវព្រះធម្មា បញ្ជាក់នាមថា-ធម៌អភិធម្ម ។
សងគុណមាតា-ដែលមានគុណធំ លើព្រះបរម-សម្ពុទ្ធថ្លៃថ្លា
ទីប្រាំបីកាលអង្គ-ព្រះសាស្តា ផ្ទំក្រោមដើមសាល-ព្រឹក្សទាំងគូ ។
ពេលនោះឯងហើយ-ព្រះសព្វញ្ញូ ព្រះអង្គជាគ្រូ-យាងចូលនិព្វាន
ឋានធំប្រាំបី-កន្លែងនេះមាន ប្រតិស្ឋាន-ក្នុងជម្ពូទ្វីប ។
ជាទីកន្លែង-មនុស្សនិងទេវតា មានចិត្តជ្រះថ្លា-ចូលទៅយល់យល់
ខ្ញុំសូមក្រាបថ្វាយ-បង្គំឆ្ពោះដល់ ឋានធំនិមល-ប្រាំបីនោះឯង ។
សូមសុខចម្រើន-កើតយូរអង្វែង.ទុក្ខទោសចំបែង-កុំកើតមានឡើយ ។
( ស្រង់តាមខ្សែអាត់សម្លេង MP3 )

**៣២៧-** ត្រូវចេះប្រមាណខ្លួន ទើបចាំមួនរក្សាខ្លួនបាន ។
ការអស់ទៅនៃតណ្ហា ឈ្នះអស់សេចក្តីទុក្ខទាំងពួង ។

# បានមកស្រុកព្រះ

បានមកស្រុកព្រះសប្បាយណាស់ ទាំងក្មេងទាំងចាស់គួរជ្រះថ្លា
អ្នកដែលធ្លាប់កាចប្រែរាបសា ខឹងខុសយ៉ាងណាចេះអត់ទ្រាំ ។
ព្រោះតែព្រះគុណបុណ្យបារមី នៃព្រះជិនស្រីប្រោសរៀបចំ
សម្ដែងព្រះធម៌ដ៏ឧត្ដម ដឹកនាំសត្វលោកឱ្យផុតភ័យ ។
ទោះជាបាត់អង្គព្រះទ្រង់ញាណ ស្ដេចទ្រង់និព្វានទៅហើយក្ដី
សល់តែព្រះស្តូបព្រះចេតិយ យើងខ្ញុំប្រុសស្រីសូមវន្ទា ។
សូមថ្វាយបង្គំព្រះពុទ្ធស្ថាន ដែលមានប៉ុន្មានឋាននានា
លង្កានេប៉ាល់ទាំងឥណ្ឌា យកជាពំនឹងពឹងតទៅ ។

( ស្រង់ចាក សៀវភៅជំនួយសតិ ភាគទី ១៤ ទំព័រ ៣១៩ )

( ដោយឧបាសក គុយ -សុធន )

**៣៦៧-** មនុស្សមានចិត្តខ្ពស់ មិនឱ្យជម្លោះរីករាលដាល ។

# សីលប្រាំ

ខ្ញុំសូមប្រណម្យ ហត្ថទាំងគូ          ដល់ព្រះជាគ្រូ សាស្ដាចារ្យ
អរហន្តៈ ដោយជ្រះថ្លា          ដែលមាននាមថា ព្រះសម្ពុទ្ធ ។
ព្រះអង្គជាគ្រូ នៃត្រៃលោក          នាំសត្វគរគោក ឱ្យរួចផុត
ចេញចាកវដ្ដៈ គួរតក់ស្លុត          កិលេសរលត់ ដល់និព្វាន ។
និងសង្ឃស្រែបុណ្យ ដ៏អស្ចារ្យ          នឹកឃើញកាលណា គួរស្រេកឃ្លាន
ទៅវត្តទៅភ្នំ បរិច្ចាគទាន          ទោះក្រធនធាន ក៏រំលែក ។
ហើយខ្ញុំក៏សូម រំលឹកដល់          ព្រះធម៌មានផល ច្រើនអនេក
បើបានស្គាល់ហើយ រមែងស្រែក          ថាធម៌ល្អឯក គ្មានអ្វីផ្ទឹម ។
ពេលនេះខ្ញុំនឹង បានបរិយាយ          រៀបរាប់បកស្រាយ ដោយសន្សឹម
អំពីសីលប្រាំ យ៉ាងញញឹម          ដោយក្ដីសង្ឃឹម ថាធម៌ល្អ ។
សីលប្រាំជាឫស ជាកំណល់          ឈោងចាប់កុសល ច្រើនគំនរ
ប្រៀបដូចប្រព័ន្ធ នៃខ្សែវល្លិ          ខ្ញុំនឹងក្រោកឈរ រាប់ឥឡូវ ។
ទីមួយបាណា តិបាតា          បងប្អូនន័យថា កុំយោរយៅ
ព្រោះប្រយោជន៍ខ្លួន ក៏ត្រាច់ទៅ          សម្លាប់តម្រូវ តាមចង់បាន ។
ទីពីរអទិន្នា ទាននេះណា          ដោយចិត្តប្រាថ្នា ដ៏សាមាន្យ

ក៏លួចប្លន់យក ព្រោះចង់បាន ដែលម្ចាស់គេគ្មាន ពោលថាឱ្យ ។
ចំណែកទីបី គឺកាមេ ទាំងយើងទាំងគេ ត្រូវចេះស្បើយ
កូនប្រពន្ធគេ សូមកុំឡើយ ត្រូវគិតថយក្រោយ ដល់គ្រួសារ ។
ចំណែកទីបួន អ្នកគួរយល់ ដែលព្រះទសពល ហៅមុសា
កុំកុហកគេ ចូរប្រាថ្នា ពោលនូវពាក្យណា ជាសច្ចៈ ។
ទីប្រាំសុរា សីលចុងក្រោយ អ្នកកុំផឹកឡើយ នាំអួលអាក់
ស្រាចូលពោះហើយ ហ៊ានកាប់ចាក់ ដែលជាប់ច្រវាក់ ទើបភ្ញាក់ខ្លួន។
បើបានដឹងហើយ ជាការល្អ កុំនៅរ៉ែ សម្ងំពួន
តាំងចិត្តរក្សា ឱ្យមាំមួន ខំប្រឹងថែខ្លួន ឱ្យត្រចង់ ។
សូមអស់បងប្អូន បានជ្រាបថា បើគ្មានសីលា នៅជាប់អង្គ
នោះដូចកំពុង ដើរតម្រង់ ចូលភ្លើងព្រោះចង់ បំផ្លាញប្រាណ ។
ដូច្នោះខ្ញុំសូម តាំងប្រាថ្នា ទោះជាតិណាៗ សូមឱ្យបាន
ជួបសីលរហូត កុំបីខាន អាយុប៉ុន្មាន ក៏រក្សា ។
ជាទីបញ្ចប់ ខ្ញុំសូមទោស រៀងរាល់កំហុស ពាក្យវាចា
ក្រែងប៉ះលោកអ្នក នូវឃ្លាណា សូមលោកមេត្តា ត្បិតមិនចង់ ។

ហើយខ្ញុំក៏សូម ប្រាប់បញ្ជាក់ បើសីលលោកអ្នក បានធ្ងរផង់
លោកអ្នកឈ្មោះថា បានសាងសង់ ទីពឹងជាប់អង្គ លែងភ័យព្រួយ ។

( ដោយ ឧបាសក រស់-សេរីវ ណ្ណាត )

## សុខព្រោះ ...

សុខព្រោះមិនមាននូវក្តីប្រមាទ សុខព្រោះឱឃាតរម្ងាប់សង្ខារ
សុខព្រោះមិនព្យាបាទនឹងនរណា សុខព្រោះចិន្តាប្រាសក្តីកង្វល់ ។
សុខព្រោះសន្តោសតាមមានតាមបាន សុខព្រោះសន្តានអប់រំដិតដល់
សុខព្រោះបុណ្យព្រេងតាមមកឱ្យផល សុខព្រោះការផ្តល់នូវធម្មទាន ។
សុខព្រោះការកើតនៃអង្គព្រះពុទ្ធ សុខព្រោះរលត់អស់ឧបាទាន
សុខក្រៃលែងសុខគឺព្រះនិព្វាន ព្រោះអីលែងមានកើតចាស់ឈឺស្លាប់ ។

( ដោយ ឧបាសក ជា-ទូច )

២៩៥- មនុស្សស្អាតព្រោះធ្វើល្អ មិនចេះក្រព្រោះចេះគ្រប់ ។
២៦៣- រូបល្អ តទៅមុខនឹងចាស់ ចិត្តល្អ ល្អណាស់ចាស់បារមី ។
២៣៨- ប្រាប់បុណ្យញយៗនឹងថយសទ្ធា ប្រាប់ត្រូវផលាសទ្ធាចម្រើន ។

# ធម៌សូត្រឧទ្ទិសមគ្គផល

ទានដែលខ្ញុំបានធ្វើហើយ ព្រះគុណអើយសូមសច្ចា
ឧទ្ទិសផលនេះណា ជូនមាតាបិតាខ្ញុំ ។
ជីដូននិងជីតា គ្រូអាចារ្យទាំងតូចធំ
ញាតិមិត្តគ្រប់និគម មកជួបជុំទទួលផល ។
ដែលកូនចៅបានធ្វើ នូវអំពើជាកុសល
សូមទានឱ្យបានដល់ ទោះមណ្ឌលឆ្ងាយយ៉ាងណា ។
កុសលទាំងអស់ហ្នឹង សូមទីពឹងលើទេវតា
ដែលមានចិត្តមេត្តា នាំផលាទាំងអស់នេះ ។
ទៅជូនឱ្យខ្ញុំផង ដូចបំណងកុំបីធ្វេស
កូនចៅនៅឯណេះ មិនប្រហែសបញ្ជូនមក ។
សូមមានចិត្តរីករាយ ដោយសប្បាយទទួលយក
កូនចៅបានលៃលក បញ្ជូនមកលោកគ្រប់ប្រាណ ។
ដើម្បីសោយកម្សាន្ត សូមឱ្យបាននូវសុខជា
កូនចៅទាំងអស់គ្នា បានបូជាជូនទៅហោង ។

ទានសីលយើងទាំងឡាយ　　សូមផ្សព្វផ្សាយដល់ញាតិមិត្ត
ទៅកើតទីឆ្ងាយជិត　　មានវិបត្តិយ៉ាងណាក្តី ។
សូមឱ្យរួចរំដោះ　　ចាកទុក្ខទោសគ្រោះចង្រៃ
បានសុខរៀងរាល់ថ្ងៃ　　ដរាបដល់និព្វានហោង ។

## ធម៌សូត្រឧទ្ទិសមគ្គផល មួយទៀត

សូមឱ្យអ្នកទាំងឡាយ　　សុខសប្បាយទាំងអស់គ្នា
កុំឱ្យមានរោគា　　ព្រមទាំងញាតិមិត្តសន្តាន ។
ចូរខំប្រឹងប្រព្រឹត្ត　　សាងសុចរិតធម៌ឱ្យបាន
សព្វថ្ងៃសាសនាមាន　　ខំធ្វើទានសីលភាវនា ។
កើតមកក្នុងលោកីយ៍　　ជនប្រុសស្រីមានវាសនា
ខំរៀនសូត្រធម៌អាថ៌　　ទាន់សាសនាព្រះទ្រង់ញាណ ។
ត្បិតយើងមិនស្គាល់ផ្លូវ　　នឹងដើរទៅព្រះនិព្វាន
ជាទីសុខក្សេមក្សាន្ត　　លះបង់បានចាកមន្ទិល ។
ជាធម៌ប្រពៃពិត　　វិសេសសុទ្ធនោះឯងណា
កាត់បង់នូវអវិជ្ជា　　គឺបណ្តាញកិលេសហោង ។

# កិច្ចសំខាន់ ៧ ក្នុងព្រះពុទ្ធសាសនា

## ថ្ងៃ ១៥ កើត ខែអាសាឍ ( **អាសាឡ្ហបូជា** )

១- ព្រះអង្គ ទ្រង់យាងចុះចាប់បដិសន្ធិ

២- ព្រះអង្គ ទ្រង់យាងចេញសាងព្រះផ្នួស

៣- ព្រះអង្គ ទ្រង់សម្តែងបឋមទេសនា

៤- ព្រះអង្គ ទ្រង់ចាប់ផ្តើមឱ្យមានព្រះសង្ឃ

៥- ព្រះអង្គ ទ្រង់សម្តែងយមកបាដិហារិយ៍

## ១៥ កើត ខែពិសាខ ( វិសាខបូជា )

១- ព្រះពុទ្ធទីបង្ករព្យាករ ព្រះសុមេធបណ្ឌិត ជានិយតពោធិសត្វ និងព្យាករ នាងសុមិត្តា ជាកន្សែសារពេជ្ជ

២- ព្រះអង្គ ទ្រង់ប្រសូត ( សហជាតិទាំង ៧ កើតឡើងក្នុងពេលជំណាលគ្នា គឺព្រះពោធិព្រឹក្ស ១ ព្រះនាងភទ្ទាកច្ចានា ១ ព្រះអានន្ទ ១ កាឡុទាយីអាមាត្យ ១ ឆន្នអាមាត្យ ១ សេះកណ្ឋកៈ ១ និងកំណប់ទ្រព្យសម្រាប់ស្តេចចក្រពត្តិ ១ )

៣- ព្រះអង្គ ទ្រង់ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ

៤- ព្រះអង្គ ទ្រង់បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ។

<u>១៥ កើត ខែមាឃ ( មាឃបូជា )</u>

១- ព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ត្រាស់សម្ដែងឱវាទបាតិមោក្ខ ( ចតុរង្គសន្និបាត គឺជាថ្ងៃព្រះចន្ទភ្លឺច្បាស់ល្អ ១ ព្រះភិក្ខុសង្ឃចំនួន ១២៥០ អង្គ សុទ្ធតែជាព្រះអរហន្តខីណាស្រព ១ ជាឯហិភិក្ខុទាំងអស់ ១ មកជួបជុំគ្នាដោយមិនបានណាត់គ្នាទុកជាមុន ១ )

២- ព្រះអគ្គសាវ័កស្ដាំ គឺព្រះធម្មសេនាបតីសារីបុត្តបានសម្រេចព្រះអរហត្តផល

៣- ព្រះសម្មាសម្ពុទ្ធ ទ្រង់ដាក់ព្រះជន្មាយុសង្ខារ ។

<u>១៥ កើត ខែអស្សុជ ( អស្សុជបូជា )</u>

ព្រះសម្មាសម្ពុទ្ធ ទ្រង់យាងចុះចាកឋានតាវត្តិង្ស ។

# ពុទ្ធកិច្ច ៥ ប្រការ ដោយសង្ខេប

១- កិច្ចក្នុងបុរេភត្ត  : ពេលព្រឹកទ្រង់យាងបិណ្ឌបាត

២- កិច្ចក្នុងបច្ឆាភត្ត  : ពេលល្ងាចទ្រង់សម្តែងធម៌ទេសនា

៣-កិច្ចក្នុងបឋមយាម  : ពេលព្រលប់ទ្រង់ប្រទានឱវាទដល់ភិក្ខុសង្ឃ

៤- កិច្ចក្នុងមជ្ឈិមយាម  : ពេលអធ្រាត្រទ្រង់ដោះប្រស្នាទេវតា

៥- កិច្ចក្នុងបច្ឆិមយាម  : ពេលនេះចែកចេញជា ៣ ចំណែកគឺ : ទ្រង់យាងចង្រ្កម ១ ទ្រង់សម្រេចសីហសេយ្យាសនៈផ្អៀងទៅខាងស្តាំ ១ ពេលជិតភ្លឺទ្រង់ប្រមើលមើលឧបនិស្ស័យសត្វលោក ១ ។

( ការប្រមើលមើលឧបនិស្ស័យសត្វលោក ក្នុង ១ ថ្ងៃ ១ យប់ មាន ២ ផង គឺក្នុងពេលជិតភ្លឺ ទ្រង់ប្រមើលមើលពីកណ្តាប់មាត់ ចក្រវាល រហូតមកដល់ព្រះគន្ធកុដិ និងក្នុងពេលល្ងាច ទ្រង់ប្រមើលមើល ពីព្រះគន្ធកុដិ រហូតទៅដល់កណ្តាប់មាត់ចក្រវាល ។)

៣១៤- ងាយណាស់ត្រង់មាត់ថា លំបាកអស្ចារ្យត្រង់ការប្រព្រឹត្ត ។

២៣១- ធ្វើត្រូវហើយតែមិននិយាយ ល្អជាងនិយាយត្រូវហើយមិនធ្វើ ។

# ការពិចារណា របស់សុមេធបណ្ឌិត

( ស្រង់ចាក ព្រះសុត្តន្តបិដក ភាគ ៧៧ ទំព័រ ២២ )

កាលនោះ តថាគតនៅក្នុងទីស្ងាត់ ក៏គិតយ៉ាងនេះថា ធម្មតាភពថ្មីទៀតតែងនាំមកនូវសេចក្តីទុក្ខ ការបែកធ្លាយនៃសរីរៈ ក៏នាំមកនូវសេចក្តីទុក្ខដូចគ្នា ( សេចក្តីស្លាប់ប្រកបដោយមោហៈ នាំមកនូវទុក្ខ រូបដែលជរាញាំញីហើយក៏នាំមកនូវទុក្ខ ) អាត្មាអញមានជាតិជាធម្មតា មានជរាជាធម្មតា មានព្យាធិជាធម្មតា អាត្មាអញនឹងស្វែងរកព្រះនិព្វាន ដែលមិនចាស់ មិនស្លាប់ ជាទីក្សេមក្សាន្ត ។

បើដូច្នេះ អាត្មាអញគួរតែលះបង់កាយស្អុយនេះ ដែលពេញដោយសាកសពផ្សេង ៗ ជាអ្នកមិនអាឡោះអាល័យ មិនមានសេចក្តីត្រូវការ ហើយនឹងចេញទៅ ។ ផ្លូវនោះនឹងមានពិត ផ្លូវនោះមិនមែនជាមិនមានហេតុទេ បុគ្គលអាចទៅបាន អាត្មាអញនឹងស្វែងរកផ្លូវនោះ ដើម្បីដោះខ្លួនចាកភព ។

កាលបើទុក្ខមាន សុខក៏មានយ៉ាងណា កាលបើភពមានការប្រាសចាកភព បុគ្គលគួរតែប្រាថ្នារក ក៏យ៉ាងនោះដែរ ។ កាលបើក្តៅមាន ត្រជាក់ដទៃក៏មាន យ៉ាងណា កាលបើភ្លើង ៣ ប្រការ

មាន ព្រះនិព្វានដែលបុគ្គលគួរប្រាថ្នា ក៏មានយ៉ាងនោះដែរ ។ កាលបើបាបមាន បុណ្យក៏មានយ៉ាងណា កាលបើជាតិមាន ព្រះ-និព្វានមិនមានជាតិ ដែលបុគ្គលគប្បីប្រាថ្នា ក៏មានយ៉ាងនោះដែរ ។

បុរសដែលប្រឡាក់លាមក ឃើញស្រះពេញដោយទឹក ហើយមិនស្វែងរកស្រះ ទោសនោះមិនមែនជាទោសនៃស្រះទេ យ៉ាងណាមិញ កាលបើស្រះ គឺព្រះនិព្វានមានហើយ បុគ្គលមិនស្វែងរកស្រះសម្រាប់លាងនូវកិលេសជាមន្ទិលចេញទេ ទោសនោះមិនមែនជាទោសនៃស្រះ គឺព្រះនិព្វានទេ គឺជាទោសរបស់បុរស ក៏យ៉ាងនោះដែរ ។

បុរសដែលត្រូវសត្រូវទាំងឡាយចោមព័ទ្ធហើយ កាលបើផ្លូវសម្រាប់រត់ទៅមាន តែបុរសនោះ មិនរត់ទៅ ទោសនោះមិនមែនជាទោសនៃផ្លូវទេយ៉ាងណា បុគ្គលត្រូវកិលេសរួបរឹតហើយ កាលបើផ្លូវព្រះនិព្វានមាន តែមិនស្វែងរកផ្លូវនោះ ទោសនោះមិនមែនជាទោសនៃផ្លូវនិព្វានទេ គឺជាទោសរបស់បុគ្គលនោះឯង យ៉ាងនោះដែរ ។

បុរសដែលមានជំងឺ កាលបើពេទ្យមាន តែមិនឱ្យពេទ្យនោះ ព្យាបាលជំងឺនោះទេ ទោសនោះ មិនមែនជាទោសនៃពេទ្យទេ

យ៉ាងណា បុគ្គលត្រូវជំងឺ គឺកិលេសទាំងឡាយបៀតបៀន ហើយ ដល់នូវសេចក្ដីទុក្ខ មិនស្វះស្វែងរកអាចារ្យ ទោសនោះ មិនមែន ជាទោសនៃអាចារ្យទេ គឺជាទោសរបស់បុគ្គលនោះឯង យ៉ាងនោះដែរ ។

( ឈើដូច្នោះ ) គួរតែអាត្មាអញលះបង់កាយស្អុយនេះ ដែលពេញដោយសាកសពផ្សេងៗ ចេញ គប្បីជាអ្នកមិនមានសេចក្ដី អាឡោះអាល័យ មិនមានសេចក្ដីត្រូវការរូប ហើយចេញទៅ ។

បុរសបានស្រាយសាកសព ដ៏គួរខ្ពើមរអើម ដែលជាប់ឰដ៏ក គប្បីជាអ្នកមានសេចក្ដីសុខ នៅតាមទំនើងខ្លួន មានអំណាចខ្លួនឯង យ៉ាងណាមិញ ។ អាត្មាអញគួរតែលះកាយស្អុយនេះ ដែលជាទី ប្រមូលមកនូវសាកសពផ្សេង ៗ ចេញ ហើយគប្បីជាអ្នកមិន អាឡោះអាល័យ មិនមានសេចក្ដីត្រូវការ ចេញទៅយ៉ាងនោះដែរ ។

បុរសស្ត្រីទាំងឡាយ ទៅបន្ទោបង់នូវករីសៈក្នុងបង្គន់ ហើយ ឥតមានអាឡោះអាល័យ ឥតមានសេចក្ដីត្រូវការ ដើរចេញទៅ យ៉ាងណាមិញ ឯអាត្មាអញនឹងលះបង់នូវកាយស្អុយនេះ ដែលពេញ ដោយសាកសពផ្សេង ៗ ចេញទៅ ដូចបុរសស្ត្រីទាំងឡាយ ដែល បន្ទោបង់វច្ចៈក្នុងបង្គន់ ដូច្នោះឯង ។

ម្ចាស់ទូកទាំងឡាយ តែងលះបង់ទូកចាស់ ដែលពុកផុយលិចចូលទឹក ឥតមានអាឡោះអាល័យ ឥតត្រូវការវិញ យ៉ាងណាមិញ អាត្មាអញនឹងលះបង់នូវកាយនេះ ដែលមានរន្ធ ៩ ហូរជានិច្ចហើយចេញទៅ ដូចជាម្ចាស់ទូក លះចោលទូកចាស់ ដូច្នោះឯង ។

បុរសកាលដើរទៅជាមួយនឹងពួកចោរ យកទ្រព្យជាប់ទៅផង ឃើញភ័យអំពីការខូចខាតទ្រព្យ ក៏លះបង់ ហើយដើរទៅ យ៉ាងណាកាយនេះ ក៏មានឧបមាស្មើដោយមហាចោរ អាត្មាអញនឹងលះបង់កាយនេះចេញ ព្រោះខ្លាចខូចខាតកុសលធម៌ យ៉ាងនោះដែរ ។

លុះតថាគត គិតឃើញយ៉ាងនេះហើយ ក៏ឱ្យទ្រព្យជាច្រើនរយកោដិ ដល់ពួកជនដែលមានទីពឹង និងពួកជនដែលឥតទីពឹង ហើយចូលទៅកាន់ព្រៃហិមពាន្ត ។ មានភ្នំមួយ ឈ្មោះធម្មិក នៅជិតព្រៃហិមពាន្ត តថាគតធ្វើអាស្រម សាងបណ្ណសាលាក្បែរភ្នំនោះ ។

**អណ្ដាតជាអាទិ៍កន្លង បានសុខទុក្ខផងក៏ព្រោះអណ្ដាត ។**

# ពុទ្ធការកធម៌ បារមី ១០

( ស្រង់ចាក ព្រះសុត្តន្តបិដក ភាគ ៧៧ ទំព័រ ៤២ )

កាលនោះ តថាគតកំពុងជ្រើសរើស ក៏បានឃើញ**ទានបារមី** ជាដំបូង ជាគន្លងធំ ដែលពោធិសត្វទាំងឡាយ អំពីបុរាណ ធ្លាប់សន្សំមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទានធ្វើនូវ**ទានបារមី** ជាដំបូងនេះ ឱ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវ**ទានបារមី**ចុះ ។

ក្អមដែលមានទឹកពេញ បុគ្គលណាមួយ ផ្កាប់ចុះ ចាក់មិនឱ្យសល់ទឹក ទឹកមិនជក់នៅក្នុងក្អមនោះ យ៉ាងណា អ្នកបើឃើញពួកស្មូមមក ទោះថោកទាប ខ្ពង់ខ្ពស់ ឬមធ្យម ចូរឱ្យទានកុំឱ្យសេសសល់ ឱ្យដូចជាក្អមដែលគេផ្កាប់ដូច្នោះ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឱ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញ**សីលបារមីទី ២** ដែលពោធិសត្វទាំងឡាយ អំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកឯងចូរសមាទាន

ធ្វើនូវ**សីលបារមីទី ២** នេះ ឱ្យមាំមួន បើអ្នកចង់លុះនូវពោធិ-ញ្ញាណ ចូរបំពេញនូវ**សីលបារមី**ចុះ ។

សត្វចាមរី ( កាលឃើញ ) រោមកន្ទុយចំពាក់នឹងរបស់អ្វីមួយ ស៊ូស្លាប់ក្នុងទីនោះ មិនព្រមផ្តាច់កន្ទុយចោលឡើយ យ៉ាងណាមិញ អ្នកចូលបំពេញនូវសីលទាំងឡាយ ក្នុងភូមិទាំង ៤ ចូររក្សាសីលសព្វកាល ឱ្យដូចជាសត្វចាមរីរក្សាកន្ទុយ យ៉ាងនោះចុះ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណឱ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញ**នេក្ខម្មបារមីទី ៣** ដែលពោធិសត្វទាំងឡាយ អំពីបូរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទានធ្វើនូវ**នេក្ខម្មបារមីទី ៣** នេះ ឱ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវ**នេក្ខម្មបារមី**ចុះ ។

បុរសដែលជាប់នៅក្នុងគុក អស់កាលដ៏យូរ ត្រូវសេចក្តីទុក្ខលៀតលៀនហើយ រមែងមិនញ៉ាំងសេចក្តីត្រេកអរ ឱ្យកើតឡើងក្នុងគុកនោះទេ រមែងស្វែងរកការរួច (ចាកគុកនោះ ) យ៉ាងណា

អ្នកចូរឃើញនូវភពទាំងអស់ ដូចជាគុកចុះ ចូរបែរមុខទៅរកនេក្ខម្មៈ ដើម្បីរួចចាកភព យ៉ាងនោះដែរ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរក ពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឱ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញ**បញ្ញាបារមីទី ៤** ដែលពោធិសត្វទាំងឡាយ អំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើនូវ**បញ្ញាបារមីទី ៤** នេះ ឱ្យមាំមួន បើអ្នកចង់ដល់នូវពោធិញ្ញាណ ចូរបំពេញនូវ**បញ្ញាបារមី**ចុះ ។

ភិក្ខុកាលប្រព្រឹត្តបិណ្ឌបាត មិនរំលងនូវត្រកូលទាំងឡាយ ទោះថោកទាប ខ្ពង់ខ្ពស់ ឬមធ្យម រមែងបានចង្ហាន់ល្មមញុំាងអត្តភាពឱ្យប្រព្រឹត្តទៅ យ៉ាងណា អ្នកបើសាកសួរជនជាអ្នកប្រាជ្ញ សព្វកាល នឹងដល់នូវ**បញ្ញាបារមី** ហើយបានលុះនូវពោធិញ្ញាណមិនខាន ក៏យ៉ាងនោះដែរ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឱ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក

ក៏បានឃើញ**វីរិយបារមីទី ៥** ដែលពោធិសត្វទាំងឡាយ អំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើនូវ**វីរិយបារមីទី ៥** នេះ ឱ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវ**វីរិយបារមី**ចុះ ។

សត្វសីហៈ ជាស្តេចនៃម្រឹគ មានព្យាយាមមិនរួញរា មានចិត្តផ្គូផ្គងសព្វកាល ក្នុងការអង្គុយ ឈរ ដើរ យ៉ាងណា អ្នកគួរផ្គូផ្គងព្យាយាមឱ្យមាំមួន ក្នុងភពទាំងពួង យ៉ាងនោះចុះ លុះដល់នូវ**វីរិយបារមី**ហើយ នឹងបានសម្រេចពោធិញ្ញាណមិនខានឡើយ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណឱ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញ**ខន្តីបារមីទី ៦** ដែលពោធិសត្វទាំងឡាយ អំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើនូវ**ខន្តីបារមីទី ៦** នេះ ឱ្យមាំមួន អ្នកកុំមានចិត្តបែកជាពីរ ក្នុង**ខន្តីបារមី**នោះ នឹងបានដល់នូវពោធិញ្ញាណមិនខានឡើយ ។

ធម្មតាផែនដី រមែងអត់ទ្រាំចំពោះវត្ថុទាំងពួង ទោះស្អាតក្តី មិនស្អាតក្តី ដែលគេដាក់ចុះហើយ រមែងមិនធ្វើនូវសេចក្តីថ្នាំងថ្នាក់ និងសេចក្តីត្រេកអរឡើយ យ៉ាងណា ។ អ្នកក៏គួរអត់ទ្រាំនូវការរាប់អាន និងការមើលងាយ របស់ពួកជនទាំងពួង យ៉ាងនោះដែរ លុះដល់នូវ**ខន្តិបារមី**ហើយ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណឱ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញ**សច្ចបារមីទី ៧** ដែលពោធិសត្វទាំងឡាយ អំពីបុរាណធ្លាប់សេពធ្លាប់អាស្រ័យមក (ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើនូវ**សច្ចបារមីទី ៧** នេះ ឱ្យមាំមួន អ្នកកុំមានពាក្យបែកជាពីរ ក្នុង**សច្ចបារមី**នោះ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។

ធម្មតាផ្កាយព្រឹក ជាជញ្ជីងរបស់លោក ព្រមទាំងទេវលោក រមែងមិនឃ្លាតចាកវិថី ក្នុងរដូវភ្លៀង ឬហេមន្តរដូវឡើយ យ៉ាងណា ។ អ្នកកុំឃ្លាតចាកវិថី ក្នុងសច្ចៈទាំងឡាយ យ៉ាងនោះដែរ លុះដល់នូវ

**សច្ចបារមី**ហើយ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណេះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឱ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញ**អធិដ្ឋានបារមីទី ៨** ដែលពោធិសត្វទាំងឡាយ អំពីបូរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទានធ្វើនូវ**អធិដ្ឋានបារមីទី ៨** នេះ ឱ្យមាំមួន អ្នកកុំញាប់ញ័រ ក្នុង**អធិដ្ឋានបារមី**នោះ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។

ភ្នំថ្មឥតកម្រើក តាំងនៅស៊ប់ មិនរញ្ជួយដោយខ្យល់ដ៏ខ្លាំងក្លា រមែងតាំងនៅក្នុងទីរបស់ខ្លួនដដែល យ៉ាងណា អ្នកចូរកុំកម្រើកក្នុង**អធិដ្ឋានបារមី**សព្វកាល យ៉ាងនោះដែរ លុះដល់នូវ**អធិដ្ឋានបារមី**ហើយ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណេះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឱ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញ**មេត្តាបារមីទី ៩** ដែលពោធិសត្វទាំងឡាយ អំពីបូរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក

( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទានធ្វើនូវ**មេត្តាបារមីទី ៩** នេះ ឱ្យមាំមួន អ្នកចូរកុំឱ្យមានបុគ្គលដទៃស្មើដោយមេត្តា បើអ្នកចង់លុះនូវពោធិញ្ញាណ ។

ធម្មតាទឹក រមែងផ្សព្វផ្សាយត្រជាក់ស្មើ ចំពោះជនទាំងល្អ ទាំងអាក្រក់ រមែងកម្ចាត់បង់នូវធូលី និងមន្ទិល យ៉ាងណា ។ អ្នកចូរ ចម្រើនមេត្តាឱ្យស្មើ ចំពោះមិត្ត និងសត្រូវ យ៉ាងនោះដែរ លុះដល់នូវ **មេត្តាបារមី**ហើយ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើស ពិសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណឱ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសពិសរក ក៏បានឃើញ**ឧបេក្ខាបារមីទី ១០**ដែលពោធិសត្វទាំងឡាយ អំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធ-បណ្ឌិត ) អ្នកចូរសមាទាន ធ្វើនូវ**ឧបេក្ខាបារមីទី ១០** នេះ ឱ្យមាំមួន អ្នកគួរជាបុគ្គលដូចជា ជញ្ជីងដ៏មាំមួន នឹងបានសម្រេចពោធិញ្ញាណមិនខានឡើយ ។

ធម្មតាផែនដី តែងព្រងើយកន្តើយ ចំពោះវត្ថុមិនស្អាតក្តី ស្អាតក្តី ដែលគេដាក់ចុះហើយ តែងវៀរចាកសេចក្តីក្រោធ និងសេចក្តីត្រេកអរ ចំពោះវត្ថុទាំងពីរនោះ យ៉ាងណា អ្នកចូរធ្វើខ្លួនឱ្យដូចជាជញ្ជីង ចំពោះសុខ និងទុក្ខ សព្វកាល យ៉ាងនោះដែរ អ្នកលុះដល់នូវ**ឧបេក្ខាបារមី**ហើយ នឹងបានសម្រេចសម្ពោធិញ្ញាណពុំខាន ។

ធម៌ទាំងឡាយណា ជាគ្រឿងញ៉ាំងពោធិញ្ញាណឱ្យសម្រេច ធម៌ទាំងនោះ មានក្នុងលោកត្រឹមតែប៉ុណ្ណោះ ពុទ្ធការកធម៌ដទៃក្រៅអំពីបារមី ១០ នោះ មិនមានទេ អ្នកចូរតាំងនៅក្នុងបារមីធម៌ទាំង ១០នោះ ឱ្យមាំមួនចុះ ។

កាលតថាគត ពិចារណានូវបារមីទាំងនេះ ដោយសភាវសរស-លក្ខណៈ ( លក្ខណៈនៃសភាវៈ ដែលមានកិច្ចនាទី ) ផែនដីទាំងមួយម៉ឺនលោកធាតុ ក៏ញាប់ញ័រដោយតេជៈនៃធម៌ ។ ផែនដីកម្រើកបន្លឺឡើងដូចជាឃ្នាបអំពៅ ដែលត្រូវគេគាប ឬចក្កយន្តប្រេង ត្រូវគេគាបហើយ (រមែងវិលញ័រ) យ៉ាងណា ផែនដីក៏ញាប់ញ័រ យ៉ាងនោះដែរ ។

៣៣៩- កុំសាងសត្រូវ  កុំនៅជិតពាល ។

៣០០- ការតាំងចិត្ត ជាមិត្តនឹងសេចក្តីសម្រេច ។

# សំវេជនីយដ្ឋាន

ទីកន្លែងដែលគួរឱ្យកើតការសង្វេគ ៤ កន្លែងដែលគួរឃើញរបស់កុលបុត្រអ្នកមានសទ្ធា ដោយរលឹកឃើញថា

ព្រះតថាគត ទ្រង់ប្រសូត **ក្នុងទីនោះ ១**

ព្រះតថាគត ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ **ក្នុងទីនោះ ១**

ព្រះតថាគត បានសម្តែងនូវអនុត្តរធម្មចក្ក **ក្នុងទីនោះ ១**

ព្រះតថាគត បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ **ក្នុងទីនោះ ១** ។

**២១៥**- ធ្វើល្អមិនចេះប្រមាណ អាចរំខានអ្នកដទៃ ។

**២២៣**- សេចក្តីល្អមានច្រើនណាស់ ប៉ុន្តែខ្វះអ្នកធ្វើល្អ ។

**៣១៤**- បើនឹកខឹងអ្នកដទៃ ត្រូវលក់លែសម្លាប់ក្រោធ ។

**៣០៤**- ត្រូវគ្រប់គ្រងក្រោធ តែបើឆោតក្រោធគ្រប់គ្រងវិញ ។

**២៣៩**- បើចង់កំហឹងចិត្តយើងខឹងកើន មេត្តាគេច្រើនចិត្តយើងត្រជាក់ ។

**៣២៥**-មនុស្សរស់ព្រោះមានទ្រព្យ មានមនុស្សងាប់ព្រោះទ្រព្យដែរ

ដូចចេកឫស្សីស្លាប់ព្រោះផ្លែ រីងជីវីស្លាប់ព្រោះភ្លូក ។

# មង្គល ៣៨ ប្រការ

១- កិរិយាមិនសេពគប់នូវបុគ្គលពាលទាំងឡាយ ១

២- កិរិយាសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយ ១

៣- កិរិយាបូជាដល់បុគ្គលដែលគួរបូជាទាំងឡាយ ១ ។

៤- កិរិយានៅក្នុងប្រទេសដ៏សមគួរ ១

៥- ភាវៈនៃបុគ្គលបានធ្វើបុណ្យទុកហើយក្នុងកាលមុន ១

៦- កិរិយាតម្កល់ខ្លួនដោយប្រពៃ ១ ។

៧- ភាវៈនៃបុគ្គលបានស្ដាប់ បានរៀនហើយដោយច្រើន ១

៨- សិល្បសាស្ត្រ គឺសេចក្ដីឆ្លៀវឆ្លាសក្នុងហត្ថកម្ម របស់អ្នកបួស និងគ្រហស្ថ ១

៩- វិន័យដែលបុគ្គលសិក្សាដោយប្រពៃ ១

១០- វាចាដែលបុគ្គលពោលត្រឹមត្រូវ ១ ។

១១- កិរិយាបម្រើនូវមាតា ១

១២- កិរិយាបម្រើនូវបិតា ១

១៣- សេចក្ដីសង្គ្រោះដល់បុត្រ និងភរិយា ១

១៤- ការងារទាំងឡាយដែលមិនច្របូកច្របល់ ១ ។

១៥- កិរិយាបរិច្ចាគទាន ១

១៦- កិរិយាប្រព្រឹត្តនូវធម៌ ( កុសលកម្មបទ ១០) ១

១៧- សេចក្ដីសង្គ្រោះដល់ញាតិទាំងឡាយ ១

១៨- ការងារទាំងឡាយដែលមិនមានទោស ១ ។

១៩- កិរិយាមិនត្រេកអរក្នុងបាប និងកិរិយាវៀរចាកបាប ១

២០- សេចក្ដីសង្រួមចាកកិរិយាផឹកនូវទឹកស្រវឹង ១

២១- សេចក្ដីមិនប្រមាទក្នុងធម៌ទាំងឡាយ ១ ។

២២- សេចក្ដីគោរពចំពោះបុគ្គលដែលគួរគោរព ១

២៣- កិរិយាប្រព្រឹត្តបន្ទាបនូវខ្លួន ( ឱ្យទន់ភ្លន់ ) ១

២៤- សេចក្ដីត្រេកអរ ( សន្ដោស ) ចំពោះរបស់ដែលមាន ១

២៥- ភាវៈនៃបុគ្គលអ្នកដឹងនូវឧបការៈ ដែលអ្នកដទៃធ្វើ ហើយដល់ខ្លួន ១

២៦- កិរិយាស្ដាប់នូវធម៌តាមកាល ១ ។

២៧- សេចក្ដីអត់ធន់ ( ខន្តិសំវរៈ ) ១

២៨- ភាវៈនៃបុគ្គលដែលគេប្រដៅបានដោយងាយ ១

២៩- កិរិយាបានឃើញ បានជួបនូវសមណៈ ( អ្នកស្ងប់រម្ងាប់នូវបាប ) ទាំងឡាយ ១

៣០- ធម្មសាកច្ឆា គឺកិរិយាសន្ទនាទៅវិញទៅមក នូវធម៌តាមកាល ( ពេលវេលា ) ១ ។

៣១- សេចក្តីព្យាយាមដុតនូវបាបធម៌ ( ក្នុងសន្តាន ) ១

៣២- កិរិយាប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ( ព្រហ្មចរិយធម៌ ) ១

៣៣- កិរិយាឃើញនូវអរិយសច្ចទាំងឡាយ ១

៣៤- កិរិយាធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ( អរហត្តផល ) ១ ។

៣៥- ចិត្តនៃបុគ្គលឯណា ដែលលោកធម៌ទាំងឡាយពាល់ត្រូវហើយមិនរំភើប ( កម្រើក ) ញាប់ញ័រ ១

៣៦- មិនមានសេចក្តីសោក ( សៅ ) ១

៣៧- មានធូលី គឺរាគៈ( កិលេសទាំងពួង ) ទៅប្រាសហើយ ១

៣៨- ជា ( សភាពនៃ ) ចិត្ត ( ដែល ) ក្សេមក្សាន្ត ១ ។

( សរុបមង្គលទាំង ៣៨ ប្រការ មាន ១០ គាថា )

ស្រង់ចាក សៀវភៅសិក្ខាបទមនុស្សល្អ ទំព័រ ៨៧

និងជំនួយសតិ ភាគទី ១៤ ទំព័រ ២៨៥ ក្នុងមង្គលសូត្រ

# សេចក្តីប្រៀបការរលឹកជាតិ
# របស់បុគ្គល ៦ ពួក

១- ពួកអន្យតិរ្ថិយ ( រលឹកជាតិបាន ៤០ កប្ប ) ដូចពន្លឺអំពិលអំពែក ( អ្នកបួសក្រៅព្រះពុទ្ធសាសនា )

២- ព្រះសាវ័កធម្មតា ( រលឹកជាតិបាន ១ រយកប្បខ្លះ ១ ពាន់កប្បខ្លះ ) ប្រៀបដូចពន្លឺប្រទីប

៣- ព្រះមហាសាវ័ក ( រលឹកជាតិបាន ១ សែនកប្ប ) ប្រៀបដូចពន្លឺ គប់ភ្លើង

៤- ព្រះអគ្គសាវ័ក ព្រះពាកុលត្ថេរ ព្រះនាងភទ្ទាកច្ចានាថេរី ( រលឹកជាតិបាន ១ អសង្ខេយ្យ និង ១ សែនកប្ប ) ប្រៀបដូចរស្មីផ្កាយព្រឹក

៥- ព្រះបច្ចេកពុទ្ធ ( រលឹកជាតិបាន ២ អសង្ខេយ្យ និង ១ សែនកប្ប ) ប្រៀបដូចរស្មីព្រះចន្ទ

៦- ព្រះសម្មាសម្ពុទ្ធទាំងឡាយ ( រលឹកជាតិបានមិនមានកំណត់ ) រមែងប្រាកដ ដូចមណ្ឌលព្រះអាទិត្យ ក្នុងសរទកាល ប្រដាប់ដោយរស្មី ១ ពាន់ដួង ។

( ស្រង់ចាក សៀវភៅបារមី ភាគ ២ )

# មហាបុរិសលក្ខណៈ ៣២ ប្រការ
# របស់ព្រះសម្មាសម្ពុទ្ធ គ្រប់ៗ ព្រះអង្គ

( ស្រង់ចាក ព្រះសុត្តន្តបិដក ភាគ ១៦ ទំព័រ ៣៤ )

១-មានព្រះបាទា ប្រតិស្ឋានស្មើ

២-មានចក្រទាំងឡាយ កើតត្រង់ផ្ទៃព្រះបាទា ប្រដាប់ដោយកាំមួយពាន់ ព្រមទាំងខ្នង និងដុំ មានចន្លោះស្មើគ្នាគ្រប់អន្លើ

៣-មានព្រះបណ្ហិ គឺកែងព្រះបាទ វែង ( បើចែកសរីរប្បទេសត្រង់នោះ ៤ ភាគ ពីរភាគជា ចុងព្រះបាទ មួយភាគជា កព្រះបាទ មួយភាគទៀត ជាព្រះបណ្ហិ)

៤-មានព្រះអង្គុលី គឺម្រាមព្រះហស្ត និងម្រាមព្រះបាទវែង ( ម្រាមព្រះហស្តទាំង ៤ វែងស្មើគ្នា ឯម្រាមព្រះបាទទាំង ៥ ក៏វែងស្មើគ្នាដែរ ហើយម្រាមទាំងអស់ មូលត្រសូលល្អវល្អ ដូចជាផង់មនោសិលា ដែលគេលាយប្រេងហើយលញ់ )

៥-មានផ្ទៃព្រះហស្ត និងផ្ទៃព្រះបាទ ទន់ល្វន់ ( ដូចជាដុំសំឡី ដែលគេផ្ដួចអស់មួយរយដង )

៦-មានផ្ទៃព្រះហស្ត និងផ្ទៃព្រះបាទ ប្រទាក់ដោយក្រឡា ដូចជាសំណាញ់

៧-មានព្រះបាទ ដូចជាអណ្ដែតឡើងខាងលើ ( ហាក់ដូចជាមិនជាប់គ្នានឹងខ្នងព្រះបាទ )

៨-មានព្រះជង្ឃា គឺស្នង ( ឈ្មោះមូលត្រសូល ) ស្រដៀងនឹងស្នងសត្វទ្រាយ ( ពុំនោះសោតស្រដៀងនឹងដង្ហើមស្រូវ )

៩-កាលឈរទ្រង់ព្រះសណ្ឋិត គឺឈរ មិនឱនព្រះអង្គចុះ អាចស្ទាបព្រះជាណុ គឺជង្គង់ ដោយផ្ទៃព្រះហស្តទាំង ២ បាន )

១០-មានព្រះអង្គាវយវៈ ដែលគប្បីលាក់ឱ្យកំបាំងដោយសំពត់ចិតនៅក្នុងស្រោម (ប្រហែលដូចជាអង្គជាតនៃដំរី ឬគោឈ្មោលជាដើម )

១១-មានព្រះឆវីវណ្ណគឺសម្បុរ (ឈឿងភ្លឺអន្លង ) ដូចជាសម្បុរនៃមាស

១២-មានព្រះឆវី គឺសម្បុរ ល្អិតផូរផង់ រលីងស្រិលរអិលធូលី ធូលីធ្លាក់មកត្រូវមិនជាប់ព្រះកាយ

១៣-មានព្រះលោមា គឺរោម ក្នុងរណ្ដៅមួយ ៗ តែមួយសរសៃ ៗ រាល់រណ្ដៅ

១៤-មានចុងព្រះលោមា ងឡើងលើ ជាទក្ខិណាវដ្ដ វិលវង់ព័ទ្ធជុំវិញ ទៅខាងស្ដាំ មានពណ៌ខៀវស្រស់ ដូចជាពណ៌នៃផ្កាអញ្ជ័ន

១៥-មានព្រះកាយត្រង់ ដូចជាកាយព្រហ្ម

១៦-មានព្រះមំសៈ គឺសាច់ ៧ អន្លើពេញលេញ ( គឺត្រង់ខ្នងព្រះហស្ដទាំង ២ ខ្នងព្រះបាទទាំង ២ ព្រះអង្សកូដ គឺចង្កួយស្មាទាំង ២ និងត្រង់ព្រះខន្ធប្បទេស គឺក សរីរប្រទេសទាំង ៧ អន្លើនេះ មានសាច់ពេញលេញល្អ ឥតមានឃើញសរសៃឡើយ )

១៧-មានចំណែកកន្លះព្រះកាយខាងដើម ស្រដៀងគ្នានឹងចំណែកកន្លះកាយនៃរាជសីហ៍

១៨-មានចង្អូរនៃព្រះបិដ្ឋិ គឺខ្នង ពេញបរិបូណ៌ ពេញស្មើ ឥតមានចង្អូរផតខូងកណ្ដាលឡើយ

១៩-មានទ្រង់ទ្រាយព្រះកាយ ប្រហែលនឹងបរិមណ្ឌលនៃដើមជ្រៃ គឺមានកាយ និងព្យាម ប្រវែងគ្នា ( ដូចជាជ្រៃ មានប្រវែងដើម គឺកំពស់ និងមែក មិនលើស មិនខ្វះពីគ្នាប៉ុន្មាន )

២០-មានព្រះខន្ធប្បទេស គឺព្រះសុរងមូលសម

២១-មានព្រះប្រសាទ គឺសរសៃ ល្អិតឆ្មារ ដ៏លើសលែង សម្រាប់ទទួលរសអាហារ ( មានសរសៃយ៉ាងឆ្មារល្អិត ៧ ពាន់ ប្រជុំស្រោបព្រះសុរង សម្រាប់ទទួលនាំរសអាហារ ឱ្យជ្រួតជ្រាបផ្សព្វផ្សាយក្នុងព្រះកាយទាំងមូលបានឥតមានទើសទាក់ សូម្បីអាហារយ៉ាងតិចប៉ុនគ្រាប់ល្ង ១ ដែលទ្រង់ដាក់ចុងព្រះជិវ្ហា ក៏អាចជ្រួតជ្រាបសព្វសព៌ាង្គកាយបាន )

២២-មានព្រះហនុ គឺចង្កា មានសណ្ឋានស្រដៀងនឹងចង្ការាជសីហ៍ ( ពេញបរិបូណ៌ប្រហែលដូចព្រះចន្ទ ត្រង់ថ្ងៃ ១២ កើត )

២៣-មានព្រះទន្ត គឺធ្មេញ ៤០គត់ (ខាងលើ ២០ខាងក្រោម ២០)

២៤-មានព្រះទន្ត រាបស្មើ (មិនប្រជួស ឬច្រពើស ខ្ពស់ទាបឡើយ )

២៥-មានរបៀបនៃព្រះទន្ត ជិតស្និទ្ធល្អ

២៦-មានព្រះទាឋា គឺព្រះចង្កូម ( ទាំង ៤ ) សស្អាត ( ភ្លឺរុងរឿងជាងពន្លឺផ្កាយព្រឹក )

២៧-មានព្រះជិវ្ហា ដ៏ទន់ល្មមល្មៃ

២៨-មានព្រះសូរសៀង គឺសូរសព្ទសំឡេង ក្រាងក្រអៅ ដូចជាសំឡេងនៃមហាព្រហ្ម កាលបើបញ្ចេញព្រះវាចា ឮពីរោះដូចជាសំឡេងនៃសត្វករវិក
២៩-មានព្រះនេត្រ ខៀវស្រស់ ( ត្រង់កន្លែងដែលគួរខៀវ ក៏ខៀវស្រស់ ដូចជាផ្កាត្រកៀត ឬផ្កាកណ្ដៀង ត្រង់កន្លែង ដែលគួរលឿង ក៏លឿងស្រស់ដូចជាផ្កាកណ្ណិកា ... ក្រហម ស្រស់ដូចផ្កាច្បារ ... សថ្លាត្រចះដូចផ្កាយព្រឹក ... ខ្មៅស្រស់ដូចជាផ្លែផ្ដៅ )
៣០-មានថ្លង់ព្រះនេត្រ ស្រដៀងនឹងថ្លង់ភ្នែកនៃគោ ( មានថ្លង់ព្រះនេត្រទាំង ២ ថ្លាយង់ ស្រដៀងនឹងថ្លង់ភ្នែកកូនគោសម្បុរ ក្រហមដែលទើបនឹងសម្រាលមួយរំពេច )
៣១-មានព្រះឧណ្ណាលោម គឺរោមដុះត្រង់ចន្លោះព្រះភមូ ( ចិញ្ចើម ) មានសម្បុរ សក្បុស ទន់ល្វន់ដូចជាសំឡី
៣២-មានព្រះសិរ្ស៍ ឃាក់ដូចជា ប្រដាប់ដោយក្បាំងស្រេចស្រាប់ ( រុងរឿងដូចជាព្រះមហាក្សត្រិយ៍ ដែលទ្រង់នូវក្បាំងព្រះភក្ត្រ ) ។

# លោកវិទូ

ចក្កវាឡ ១ ពោលដោយចំណែកបណ្ដោយ និងទទឹងមាន ប្រមាណ ១ លាន ២ សែន ៣ ពាន់ ៤ រយ ៥០ យោជន៍ ពោលប្រមាណដោយជុំវិញ មានបរិមណ្ឌលទាំងអស់ ៣ លាន ៦ សែន ១ ម៉ឺន ៣ រយ ៥០ យោជន៍ ( ៣៦១០៣៥០ យោជន៍ ) ។

ផែនដី ពោលដោយកម្រាស់ មានប្រមាណ ២ សែន ៤ ម៉ឺន យោជន៍ ( ២៤០០០០ យោជន៍ ) ។

ទឹកទ្រផែនដី មានកម្រាស់ប្រមាណ ៤ សែន ៨ ម៉ឺនយោជន៍ តាំងនៅលើខ្យល់ ( ៤៨០០០០ យោជន៍ ) ។

ខ្យល់ទ្រទឹក មានកម្ពស់ ៩ សែន ៦ ម៉ឺនយោជន៍ បក់ឡើង ទល់ផ្ទៃមេឃ ( ៩៦០០០០ យោជន៍ ) ។

ភ្នំសិនេរុ ខ្ពស់ជាងភ្នំទាំងឡាយ ចាក់ចុះក្នុងអន្លង់មហា សមុទ្ទ មានជម្រៅ ៨ ម៉ឺន ៤ ពាន់យោជន៍ ខ្ពស់ឡើងទៅលើ ក៏មានប្រមាណ ប៉ុណ្ណោះដូចគ្នា ( ៨៤០០០០ យោជន៍ ) ។

ភ្នំធំទាំង ៧ នេះ គឺ ភ្នំយុគន្ធរ ១ ភ្នំឥសិន្ធរ ១ ភ្នំករវិក ១ ភ្នំសុទស្សន ១ ភ្នំនេមិន្ធរ ១ ភ្នំវិនតក ១ ភ្នំអស្សកណ្ណ

១ ជារបស់ទិព្វ វិចិត្រដោយរតនៈផ្សេង ៗ ចាក់ចុះក្នុងអន្លង់មហាសមុទ្រ និងខ្ពស់ឡើង ( ខាងលើ ) តាមលំដាប់ ដោយប្រមាណពាក់កណ្តាលនៃភ្នំសិនេរុ ( ទាំងខាងក្រោម និងខាងលើ ) ហើយជាទីនៅនៃមហារាជទាំង ៤ មានយក្ស និងទេវតាជាដើម តាំងនៅដោយជុំវិញនៃភ្នំសិនេរុ ដោយអំណាចជាគ្រឿងឡោមព័ទ្ធ ។

ជម្ពូទ្វីប ( ដើមព្រីង ឈ្មោះនគៈ ) ដើមមានទំហំ ១៥ យោជន៍ បណ្តោយនៃដើម និងមែក មានប្រមាណ ៥០ យោជន៍ ទទឹងដោយជុំវិញ និងកម្ពស់ មានប្រមាណ ១ រយយោជន៍ ។

ភ្នំចក្កវាឡ ចាក់ចុះទៅក្នុងមហាសមុទ្ទ ៨ ម៉ឺន ២ ពាន់ យោជន៍ កម្ពស់ក៏មានប្រមាណប៉ុណ្ណោះដូចគ្នា ( ៨២០ ០០០ យោជន៍ ) តាំងនៅជុំវិញលោកធាតុទាំងអស់ ។

មណ្ឌលព្រះចន្ទ្រ មានប្រមាណ ៤៩ យោជន៍ ។

មណ្ឌលព្រះអាទិត្យ មានប្រមាណ ៥០ យោជន៍ ។

ជម្ពូទ្វីប ភពអសុរ អវិចីមហានរក ភពតាវត្តិង្ស មានប្រមាណ ១ ម៉ឺនយោជន៍ ( ១០ ០០០ យោជន៍ ) ។

អបរគោយានទ្វីប បុព្វវិទេហទ្វីប មានប្រមាណ ៧ ពាន់យោជន៍ ( ៧០០០ យោជន៍ ) ។

ឧត្តរកុរុទ្វីប មានប្រមាណ ៨ ពាន់យោជន៍ ។

ទ្វីបធំមួយៗ មានទ្វីបតូចជាបរិវារ ៥ រយៗ ។

លោកន្តរិក.នរក នៅចន្លោះនៃចក្កវាឡ ។

( ស្រង់ចាក អដ្ឋកថាសមន្តបាសាទិកា ភាគ ២ ទំព័រ ៣៧ )

អ្នកសូមតែងទាស់ចិត្តអ្នកឱ្យ
បើសូមញយៗ អ្នកណាគេហ៊ានដើរជិត
ជាតិជាបណ្ឌិត ត្រូវគិតមុននឹងសូម ។

ព្រះសទ្ធម្មជាស្គរជ័យ ព្រះវិន័យជារាងធំ
ព្រះសូត្រជាខ្សែរុំ ព្រះអភិធម្មជាស្បែកជាស ។
អរិយសច្ចជាអន្លង់ សម្រាប់ទូងឱ្យឮច្បាស់
សត្វលោកដេកងុយណាស់ ឮស្គរដាស់ក្រោកឡើងបាន ។

( ស្រង់ចាក សៀវភៅគិហិបដិបត្តិពិស្តារ ទំព័រ ៨៥ )

# អាយុរបស់ទេវតា

ជាន់ទី ១ ( **ចាតុម្មហារាជិកា** ) មានអាយុ ៥០០ ឆ្នាំទិព្វ គិតជាឆ្នាំមនុស្ស ៩ លានឆ្នាំ (គឺ ១ ថ្ងៃឋាននោះ ស្មើ ៥០ ឆ្នាំមនុស្ស)

ជាន់ទី ២ ( **តាវត្តឹង្ស** ) មានអាយុ ១ ០០០ ឆ្នាំទិព្វ គិតជាឆ្នាំមនុស្ស ៣៦ លានឆ្នាំ ( គឺ ១ ថ្ងៃឋាននោះ ស្មើ **១០០** ឆ្នាំមនុស្ស)

ជាន់ទី ៣ ( **យាមា** ) ២ ០០០ ឆ្នាំទិព្វ ( ១៤៤ លានឆ្នាំមនុស្ស ) គឺ ១ ថ្ងៃឋាននោះ ស្មើ **២០០**ឆ្នាំមនុស្ស

ជាន់ទី ៤ ( **តុសិត** ) ៤ ០០០ ឆ្នាំទិព្វ ( ៥៧៦ លានឆ្នាំមនុស្ស ) គឺ ១ ថ្ងៃឋាននោះ ស្មើ **៤០០**ឆ្នាំមនុស្ស

ជាន់**និម្មានរតី** ៨ ០០០ ឆ្នាំទិព្វ ( ២ ៣០៤ លានឆ្នាំមនុស្ស ) គឺ ១ ថ្ងៃឋាននោះ ស្មើ **៨០០**ឆ្នាំមនុស្ស)

ជាន់**បរនិម្មិតវសវត្តី** ១៦០០០ ឆ្នាំទិព្វ ( ៩ ២១៦ លានឆ្នាំមនុស្ស ) គឺ ១ ថ្ងៃឋាននោះ ស្មើ **១ ៦០០**ឆ្នាំមនុស្ស)

( ស្រង់ចាក សៀវភៅអភិធម្មត្ថសង្គហៈ ៩ បរិច្ឆេទ ទំព័រ ៥៨៧)

# ឧទ្ទិសបុណ្យជូនមាតាបិតា

អបអំនាម្នោសិរសាប    ឱនកាយបន្ទាបក្រាបវន្ទា
នឹងពោលសម្ដែងថ្លែងពណ៌នា    វន្ទាគោរពព្រះគុណថ្លៃ ។
មាតាបិតាបង្កើតកាយ    មានគុណជ្រាលផ្សាយហួសនិស្ស័យ
ធ្ងន់លើសប្រឹថពីឥតឧបមេយ្យ    ខ្ពស់ហួសនិស្ស័យសុមេរ៉ា ។
កាលកូនកើតនៅក្នុងឧទរ    មាតាទ្រាំទ្រគ្រប់ឥរិយា
ប្រសូតកូនរួចស្រេចកាលណា    មាតាប្រទានទឹកដោះថ្លៃ ។
បីបមថ្នាក់ថ្នមត្រាំពលាង    បញ្ចេញសូរសៀងច្រៀងបំពេ
បយោសអង្រួលសព្វកាយេ    ព្រះមេមានគុណធ្ងន់ជ្រាលផ្សាយ ។
បពិត្រលោកអ្នកមាតាបិតា    កូននឹកខ្លោចផ្សាពេកអំពាយ
តាំងពីកូនកើតមានរូបកាយ    អ្នកតែងខ្វល់ខ្វាយថែរក្សា ។
ឱះឱម្ចាស់ថ្លៃវិសេសលន់    អ្នករងទុក្ខធ្ងន់ពន់ពេកណា
ព្រោះអ្នកខំបីបាច់ស្ងួនភ្ងា    ពុំអាចពណ៌នាឱ្យអស់បាន ។
ដូច្នេះខ្ញុំសូមឱនអញ្ជលី    លើកហត្ថទាំងពីរបន្ទន់ប្រាណ
បង្គំបាទាព្រះក្សេមក្សាន្ត    ទោសខុសប៉ុន្មានសូមប្រណី ។

ម្ចាស់អើយកាលកូនទ្រហោយំ		អ្នកស្ទុះមកថ្នមត្រកងបី
ច្រៀងបំពេកូនដោយប្រិមប្រិយ		ដោយចិត្តមេត្រីផ្អែកកូនណា ។
ទឹកមូត្រទឹកមាត់លាមកផង		និងគ្រឿងសៅហ្មងផងនានា
អ្នកចាប់អ្នកកាន់អ្នកស្រវា		លាងដោយហត្ថាឥតឆ្អិតឆ្អន់ ។
បពិត្រអ្នកម្ដាយមានករុណា		បិតាមានគុណវិសេសលន់
កូនសូមគោរពព្រះគុណធ្ងន់		សូមព្រះសោភ័ណបានក្សេមក្សាន្ត ។
ហេតុនេះខ្ញុំសូមឧទ្ទិសផល		តម្កល់ចេតនាដ៏ក្លាហាន
ទានសីលភាវនាដែលកូនបាន		សាងធ្វើប៉ុន្មានជូនដល់លោក ។
សូមលោកទទួលដោយសោមនស្ស		ចិត្តខ្ញុំត្រង់ស្មោះចំពោះជាក់
ដូចកូនបានពោលពាក្យសច្ចៈ		សូមជូនទៅអ្នកឪពុកម្ដាយហោង ។

## សូមនឹកដល់គុណ

ខ្ញុំសូមនឹកដល់គុណធម៌		ប្រសើរល្អគួរជ្រះថ្លា
ព្រះពុទ្ធជាសាស្ដា		ឱ្យឈ្មោះថាអរិយទ្រព្យ ។
ញាតិកាមានប្រាំពីរ		ព្រះមុនីសម្ដែងប្រាប់

ដល់សត្វដែលមានភ័ព្វ ឱ្យស្គាល់ទ្រព្យមានខ្លឹមសារ ។
ទ្រព្យទីមួយគឺសទ្ធា យើងរាល់គ្នាគួរជ្រះថ្លា
ជឿស៊ប់ក្នុងសាសនា ថាបុណ្យបាបមានប្រាកដ ។
ទ្រព្យទីពីរគឺសីល យើងកុំខ្ជិលត្រូវកំណត់
រក្សានូវកម្មបថ ឱ្យឃ្លាត់ចត់ខាងកុសល ។
ហិរិទ្រព្យទីបី ព្រះជិនស្រីបានពន្យល់
ឱ្យខ្មាសបាបអកុសល ក្រែងប៉ះពាល់វៀរឱ្យផុត ។
ទីបួនគឺឱត្តប្បៈ បាបអបលក្ខណ៍គួរតក់ស្លុត
ខ្ពើមឆ្អើមភ័យរន្ធត់ ទើបបរិសុទ្ធកាយវាចា ។
ទីប្រាំគឺសោតៈ ស្តាប់ឱ្យជាក់ពាក្យពុទ្ធដីកា
ឱ្យសាកសួរពីធម៌អាថ៌ កម្ចាត់បង់ពួកអវិជ្ជា ។
ទីប្រាំមួយគឺចាគៈ លះលោភៈនៃអាត្មា
ធ្វើទានក្នុងសាសនា ទើបបានដល់ជាទីពឹង ។
ទីប្រាំពីរគឺបញ្ញា ពិចារណាច្រើនគ្រប់កាល
ស្តាប់ហេតុផលធ្ងន់ស្រាល ក្នុងជីវិតសត្វត្រៃភព ។

បញ្ញាត្តកុសល ត្រិះរិះយល់ហេតុសព្វគ្រប់
ទានសីលធ្វើមិនឈប់ រៀនសូត្រសព្វធម៌វិន័យ ។
ហេតុនោះពុទ្ធបរិស័ទ ប្រឹងបដិបត្តិរាល់យប់ថ្ងៃ
ដើម្បីយកនិស្ស័យ ជាបច្ច័យសុខទុក្ខឱ្យហើយ ។
ទ្រព្យសម្បត្តិក្នុងលោកា គ្មានខ្លឹមសារទេអ្នកអើយ
បន្តិចក្លាយអស់ហើយ ទៅជាដីទឹកភ្លើងខ្យល់ ។
កាលខ្លួនមិនទាន់ស្លាប់ មិនប្រញាប់ធ្វើកុសល
មច្ចុរាជទន្ទ្រានដល់ ទើបខ្វាយខ្វល់ធ្វើនឹងគេ ។
បើធ្វើទានៗសំណាល់ បើធ្វើសីលៗទំនេរ
ជិតស្លាប់ចិត្តងាករេ គ្មានបុណ្យទេទៅអបាយ ។
បើមានអរិយ ទ្រព្យ ប្រសើរគាប់ដូចបរិយាយ
លុះបែកធ្លាយរាងកាយ សុខសួគ៌នាយនិព្វានហោង ។

# វិសាខាឧទាន

សេចក្តីត្រិះរិះរបស់ខ្ញុំថា　　តើនៅពេលណាខ្ញុំបានថ្វាយទាន
នូវប្រាសាទថ្មីតាមទ្រព្យដែលមាន　　ជាវិហារទានថ្វាយចំពោះសង្ឃ ។
សេចក្តីត្រិះរិះរបស់ខ្ញុំថា　　តើនៅពេលណាខ្ញុំបានឱនអង្គ
ថ្វាយគ្រែពូកខ្នើយដោយចិត្តផ្ចិតផ្ចង់　　ចំពោះដល់សង្ឃដែលគង់ក្នុងវត្ត ។
សេចក្តីត្រិះរិះរបស់ខ្ញុំថា　　តើនៅពេលណាខ្ញុំបានថ្វាយភត្ត
ផ្សំដោយមំសៈធ្វើដោយហ្មត់ចត់　　សលាកភត្តជាអាហារទាន ។
សេចក្តីត្រិះរិះរបស់ខ្ញុំថា　　តើនៅពេលណាជួបព្រះទ្រង់ញាណ
ព្រមទាំងព្រះសង្ឃសទ្ធាខ្ញុំមាន　　ថ្វាយចីវរទានសំពត់សាច់ល្អ ។
សេចក្តីត្រិះរិះរបស់ខ្ញុំថា　　តើនៅពេលណាជួបសង្ឃបវរ
ថ្វាយភេសជ្ជៈទឹកឃ្មុំប្រេងស្ករ　　ទឹកដោះគោល្អនិងទឹកអំពៅ ។
មកដល់ឥឡូវខ្ញុំបានសម្រេច　　គ្រប់មុខស្រេចបាច់ឥតមានសល់នៅ
ខ្ញុំបានថ្វាយទានកប់ទុកយ៉ាងជ្រៅ　　ក្នុងដំណើរទៅកាន់ព្រះនិព្វាន ។

( ស្រង់ចាក សៀវភៅបទពិចារណា ទំព័រ ១២៤ )

# ព្រះធម៌ជាស្ពាន

កើតជាមនុស្សហើយ ចូរកុំកន្តើយ រកត្រើយនិព្វាន
សទ្ធាជាពូជ ដូចព្រះទូន្មាន ព្រះធម៌ជាស្ពាន
ឆ្លងវដ្តសង្សារ ។

បើជា តិរច្ឆាន ធ្វើទានម្តេចបាន ទុក្ខលុះមរណា
ឥតស្គាល់សីលទាន ពុំមានធម៌អាថ៌ ខ្វះទាំងអាហារ
ខ្លោចផ្សាលុះក្ស័យ។

កើតជាមនុស្សនេះ ជាបុណ្យពិសេស ជាលាភធំក្រៃ
កុំភ្លេចសីលទាន ស្ពានឆ្លងកពក្រៃ សុំជាប់និស្ស័យ
ព្រះពុទ្ធសាសនា ។

សទ្ធានៅរាក់ បើខ្វះវិរិយៈ ជំពាក់តណ្ហា
បើខ្វះខន្តី បាត់ក្តីមេត្តា បើខ្វះបញ្ញា
ជាប់បំណុលកម្ម ។

( **ស្រង់ចាកសៀវភៅ ធរ ៤ ប្រការ ទំព័រ ២៥០** ដោយឧបាសក គុយ សុធន)

ឃ្លាខ្លី ៗ ស្រង់ចាក សៀវភៅបទពិចារណា លោកគ្រូអគ្គបណ្ឌិត

# ធម៌ និងកំណាព្យនមស្ការ



ពុទ្ធសករាជ ២៥៥៤

ប្រមូលរៀបរៀងដោយ ខ្ញុំព្រះករុណា ខ្ញុំបាទ ស៊ុន-សុផាន

# ធម៌ និងកំណាព្យនមស្ការ



ពុទ្ធសករាជ ២៥៥៤

ប្រមូលរៀបរៀងដោយ ខ្ញុំព្រះករុណា ខ្ញុំបាទ ស៊ុន-សូផាន

ធម្មទានដោយ ឧបាសក

# អំណាចព្យនមស្ណូនៃ
# ព្រះរតនត្រ័យ



ពុទ្ធសករាជ ២៥៥៣

សព្វទានំ ធម្មទានំ ជិនាតិ

ធម្មទាន ឈ្នះអស់នូវទានទាំងពួង